សារព័ត៌មាន ខ្មែរផុស ស.រ.អា
# KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការរឿង

Issue 162 Sept 22th-Oct09.th, 2014

Free

១-ថ្នាលបណ្តុះពូជកីឡាទាត់បាល់........................០៣
៣-វិស្សមកាលបុណ្យដូរក្តៅនៅរ៉ូដអាយ្លិន.............០៤
៤-វិភាគលទ្ធផលនៃការបោះឆ្នោត.....................០៧
៥-ហេតុអ្វីក៏ វ៉ានី ម៉ម ឈ្នះឆ្នោត?......................០៩
៦-លទ្ធផលលើកដំបូងនៃការបោះឆ្នោត................១០
៧-ពហិការនៅផ្សារ ម៉ាក ឃីត បាសឃីត............១១
៨-រមណីយដ្ឋាន បុរាណវិទ្យា ភ្នំចាស់..................១៦
៩-ពាក់អាវទ្រនាប់មិនត្រឹមត្រូវអាចបង្កើន...........២១

New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិចារណកថា

# ក្តីសង្ឃឹមរបស់ពលរដ្ឋខ្មែរនឹងមកដល់


ពិន សំខុន

**វិភាគនយោបាយដោយ : ពិន សំខុន**

វិភាគនយោបាយខ្មែរផុសស.រ.អា បានធ្វើឱ្យបងប្អូនខ្មែរបានទទួលនូវការពិចារណាឯករាជ្យមួយដែលរៀងរាល់ថ្ងៃព្រឹត្តការណ៍នយោបាយបានដឹកនាំយើងពីមួយចំហ៊ានទៅមួយជំហ៊ានទៀតទៅរកភាពស្មុគស្មាញច្របូកច្របល់ពិបាកយល់ ។ តែទោះជាយ៉ាងនេះក៏ដោយក្តីយើងនៅចាំថា តាំងពីច្រើនឆ្នាំមកហើយមកទល់នឹងថ្ងៃនេះវិភាគរបស់យើងដែលបានចង្អុលទិសដើរស្របនឹងការវិវត្តន៍សង្គមខ្មែរអ្វីៗ **តទៅទំព័រទី ១៩**

# ពិធីកាន់វេនបិណ្ឌ និងបុណ្យភ្ជុំ

**រៀបរៀងដោយ : ថាច់ វណ្ណា** • វស្សន្តៈរដូវបានរំកិលជិតផុតទៅ រដូវបិណ្ឌភ្ជុំក៏បានឈានចូល **តទៅទំព័រទី ០២**


ខ្មែរផុសកាន់បិណ្ឌទី១០នៅវត្តពន្លឺពុទ្ធិចក្ក

# បទសម្ភាសន៍ជាមួយតំណាងរាស្ត្រខ្មែរ ឯកឧត្តម ប៉ុល ហំ

## គណបក្សសង្គ្រោះជាតិឡូវែលទទួលគណប្រតិភូសភាខ្មែរ

**ដោយ : ពិន សំខុន**

លោក ប៉ុលហំ នឹងសមាជិកសភាខ្មែរ២រូបទៀតដែលទើបនឹងចូលស្បត់ ហើយទទួលការ


ឯកឧត្ដម ប៉ុល ហំ (កណ្ដាល) ថតជាមួយសហគមន៍ខ្មែរនៅឡូវែល

តែងតាំងថ្មីៗ ដោយព្រះមហាក្សត្របានមកធ្វើទស្សនកិច្ចនៅឡូវែល ដើម្បីជួបប្រស្រ័យទាក់ទងនឹងសកម្មជនគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៤កន្លងទៅនេះ ។

លោក ប៉ុល ហំ ជាតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិជាប្រធានគណកម្មាធិការនាយកនឹងជាប្រធានគណកម្មការសភាទី៣ ទទួលបន្ទុកខាងផែនការនឹងវិនិយោគកសិកម្ម ។ លោកអញ្ជើញមកជួបសកម្មជនគណបក្សសង្គ្រោះជាតិនៅឡូវែលថ្ងៃទី១៤-១៥ មុននឹង **តទៅទំព័រទី ០៥**

VMART LOWELL

ចាប់បើកហើយ !



**ផ្សារម្ហូបអាស៊ី**

មានម្ហូបច្រើនមុខដល់ទៅ ១២,០០០មុខ
សាច់ស្រស់ និងម្ហូបធ្វើហើយ ម្ហូបស្រស់ៗ
មកពីបសស្តុន, ញូយ៉ក, និងគ្រប់កន្លែងទូទាំងប្រទេស
តម្លៃល្អបំផុត ! ស្រស់ថ្មីបំផុត !



អាសយដ្ឋាន 123 Church Street
Lowelll, MA 01852
**អតីតផ្សារចាត់ដំបង**

Grand Openning
Sale with
the 10%OFF



តមកពីទំព័រទី ០១

# ពិធីកាន់វេនបិណ្ឌ និងបុណ្យភ្ជុំ...

មកប្រជាពុទ្ធបរិស័ទខ្មែរទូទាំងស.រ.អា ទោះបីជាមានការរស់នៅឆ្ងាយពីភូមិស្រុកកំណើតក៏ដោយក្តី ក៏បានខិតខំប្រមូលគ្នាធ្វើចង្ហាន់ និងបច្ច័យ៤មានទាំងផ្លែផល្លាគ្រប់មុខ ព្រមទាំងផ្កាភ្ញីចំរុះគ្រប់ពណ៌ នាំគ្នាយកទៅកាន់ទីវត្តអារ៉ាម ដើម្បីថ្វាយនិងប្រគេនដល់ព្រះសង្ឃតាមប្រពៃណីរបស់ខ្លួន ។

ក្រុមកាសែតខ្មែរផុសស.រ.អាក៏បានខិតខំទៅវត្តពន្លឺពុទ្ធចក្ក ដើម្បីចុះឈ្មោះកាន់បិណ្ឌឱ្យបានទាន់ពេលនៅវេនទី១០រោច ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា នេះ ។

ឥឡូវនេះ វេនទី១០ ក៏បានឈានមកដល់ យើងបានរៀបចំពិធីដង្វាយព្រះនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត និងសំដែងធម្មទេសនាបន្ទាប់មកនឹងមានកម្មវិធីសូត្រ បរ៉ា ជាដើម ។

ក្នុងអត្ថន័យខ្លឹមសារនៃធម្មទេសនារបស់ព្រះធម្មាចារ្យ "មេត្តា បាណោ ទឹម សឿត" បានសម្តែងបុណ្យនឹងបាបសេចក្តីខ្មាស់បាបនឹងខ្លាចបាបភាសាបាលីហៅថា "ហិរិ ឧត្តប្បៈ"ព្រះអង្គបានលើកជាឧទាហរណ៍ក្នុងសង្គមមនុស្សសព្វថ្ងៃទីណាមានអំពើបាប គៀប សង្កត់ ទីនោះនឹងការបាតុកម្មដើម្បីទាមទាររកយុត្តិធម៌ ព្រះអង្គសម្តែងបន្ថែមថា : ពួកអ្នកកាសែតមានការរិះគន់អ្នកប្រព្រឹត្តបទល្មើស ក៏ជាចំណែកមួយក្នុងការដាស់តឿនសង្គមមនុស្សឱ្យចេះខ្មាស់បាបនិងខ្លាចបាបយ៉ាងដូច្នោះដែរ ។

ក្នុងកម្មវិធីនេះល្ងាចថ្ងៃ១៧ មានប្រជាមតិពុទ្ធបរិស័ទចូលរួមប្រមាណ២០នាក់ មានជាតិអាមេរិកាំងចូលរួមផងដែរ ។

ព្រឹកឡើងថ្ងៃទី១៨ កញ្ញា យើងខ្ញុំបានរៀបចំចង្ហាន់ប្រគេនព្រះសង្ឃចំរើនព្រះបរិត្តឧទ្ទិសភោគផលដល់បុព្វការីជន មានមាតាបិតាញាត្តិមិត្តសាច់សាលោហិតទាំង៧សន្តាន ដែលបានចែកឋានទៅកាន់បរលោកខាងមុខហើយនោះ សូមឱ្យអស់លោកទាំងនោះបានទទួល នូវឥដ្ឋមនុញ្ញៈផល គឺផលជាទីគាប់ចិត្តបានផុតរួចទុក្ខទោសទៅសោយសម្បត្តិនាស្ថានសុគ្គតិភពទៅហោង ។









វេនបិណ្ឌទី១០ បានឆ្លងផុតហើយ បុណ្យភ្ជុំបិណ្ឌក៏ឈានមកដល់នៅថ្ងៃ១៥រោចនេះ បើតាមគម្ពីរវិជ្ជាធរៈ"មានតំណាលថា : មានថេរៈមួយអង្គឈ្មោះថា : ព្រះឧបគុត្តត្ថេរលោកមានមហិទ្ធិរិទ្ធយ៉ាងខ្លាំងលោកបាននិមន្តទៅស្ថាននរកដើម្បីសម្តែងធម៌ទេសនាពេលដែលនិមន្តទៅដល់ក៏ប្រទះឃើញភ្លើងនៅស្ថាននរកកំពុងឆេះយ៉ាងសន្ធោសន្ធៅតែដោយបារមីព្រះអង្គក្នុងពេលនោះក៏មានផ្កាឈូកមួយលេចចេញចំពោះព្រះភ័ក្ត្រព្រះអង្គដោយមានទំហំប៉ុនកងរាជរថ រួចលោកក៏គង់លើផ្កាឈូកនោះហោះកាត់ស្ថាននរកដោយមិនមានប៉ះពាល់នៅកំដៅក្នុងឋាននរកឡើយ ។

ពេលដែលព្រះអង្គនិមន្តទៅដល់ពួកសត្វនរកទាំងនោះ មានការភ្ញាក់ផ្អើល និងគោរពកោតខ្លាចយ៉ាងខ្លាំងនូវឫទ្ធិបារមីរបស់ព្រះអង្គឧបគុត្តត្ថេរ ព្រះអង្គក៏បានត្រឡប់វិលមកស្ថានមនុស្សវិញ ។

ពួកសត្វនរកទាំងនោះ ក៏បានផ្តាំផ្ញើថា "ទូលព្រះបង្គំទាំងអស់គ្នាសព្វថ្ងៃនេះលំបាកវេទនាណាស់ ខ្លួនត្រូវអត់ចំណីអាហារ ហើយរងនឹងភ្លើងដ៏សែនក្តៅក្នុងស្ថាននរកទៀតផង ពុំដែលមានសាច់សាលោហិតណាលើកយកចំណីអាហារ ឬបច្ច័យបួនមកឧបត្ថម្ភយើងខ្ញុំឡើយ រោគាព្យាធិជំងឺដង្កាត់ក៏ច្រើនដែរ ។ ប្រសិនបើព្រះអង្គនិមន្តវិលទៅស្ថានមនុស្សលោកវិញ សូមព្រះអង្គមេត្តាជួយផ្សព្វផ្សាយឱ្យបងប្អូនញាត្តិមិត្តម៉ែឪ ជីដូនជីតារបស់ពួកខ្ញុំឱ្យនិមន្តព្រះសង្ឃដែលមកធ្វើបុណ្យកាន់បិណ្ឌ ឬដាក់ បិណ្ឌផង រួចហើយសព្វសាធុការពរផល្លានិសង្សដែលកើតមាននៅក្នុងវារៈដាក់បិណ្ឌនោះឧទ្ទិសជូនដល់ពួកខ្ញុំផង ដើម្បីជួយយិតយោងឱ្យបានឆាប់ផុតពីសេចក្តីទុក្ខទោសក្នុងស្ថាននរកនេះទៅ ។

ព្រះឧបគុត្តត្ថេរ ក៏បាននាំយកបណ្តាំទាំងនោះទៅក្រាបបង្គំទូលថ្វាយសម្តេចនៃព្រះរាជាណាចក្រកម្ពុជានាពេលនោះទៅស្តេចក៏បានអនុញ្ញាតិឱ្យផ្សព្វផ្សាយដល់ប្រជារាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជាក្នុងសម័យអង្គរឱ្យធ្វើបុណ្យដាក់បិណ្ឌ ឬកាន់បិណ្ឌក្នុងរដូវវស្សាចាប់តាំងពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៥រោចខែភទ្របទ ។ ត្រូវនឹង ថ្ងៃទី៣.៤ឬ៥ ខែតុលា ជារៀងរាល់ឆ្នាំតាំងពីពេលនោះ មករហូតដល់សព្វថ្ងៃនេះ ។

ព្រោះហេតុនេះហើយប្រជារាស្ត្រខ្មែរទោះបីជានៅទីណាក្តីតែងតែនាំគ្នាធ្វើបុណ្យដាក់បិណ្ឌព្រមទាំងបច្ច័យ៤ ដើម្បីឧទ្ទិសភាគផលកុសលដល់បុព្វការីជនមានមាតាបិតា ជីដូនជីតាទាំង៧សន្តានឱ្យបានរួចផុតពីទុក្ខទោសនឹងឈានទៅកាន់សុគតិភពផង ។

ពិធីកាន់បិណ្ឌប្រជារាស្ត្រខ្មែរយើងនៅតំបន់ខ្លះបានប្រារព្ធជាបែបពិស្តារដោយមានរៀបចំចង្ហាន់ ទិព្វ រួមជាមួយដង្វាយព្រះរាល់ពេលព្រឹករៀបដង្ហែបាយបិណ្ឌទក្សិណាជុំព្រះវិហាររាល់ពេលព្រឹករួមជាមួយនឹងសម្លេងភ្លេងពិណពាទ្យសម្លេងស្គរធំជាបទ៧ដង្ហែរួមជាមួយផង។

ក្រៅពីនេះនៅវេលារសៀលថ្ងៃ១៤រោច នឹងមានរៀបចំពិធីសែន "ដូនតា"តាមរបៀបព្រហ្មញ្ញសាសនាផងដែរ គឺរៀបចំសែនបាយម្ហូប ស្រា ម្លូ ស្លា បារី ទឹក រៀបជាពីរថាស រួចអញ្ជើញយាយ តា មានវ័យចំណាស់ អង្គុយជាប្អូនមុម រួចហើយក៏បាននាំគ្នាសូត្រគាថា នឹងពាក្យភាពឃ្លោងតាមរបៀបព្រហ្មសាសនាការប្រារព្ធបែបនេះនឹងមានធ្វើកម្ពុជាក្រោមទាំងពីបុរាណកាលរហូតមកទល់ពេលសព្វថ្ងៃ ។

រីឯសហរដ្ឋអាមេរិកវិញ ប្រជារាស្ត្រអាមេរិកាំងមួយចំនួនធំបានប្រារព្ធពិធីហាឡូវីុន (Halloween)ពិធីនេះ បានកើតមានឡើងតាមរយៈប្រទេសអង់គ្លេសបាននាំចូលមកស.រ.អាតាំងពីឆ្នាំ១៧៤៥ គេបានកំណត់ថ្ងៃធ្វើពិធីនេះ នៅថ្ងៃទី៣១ ខែតុលា ជារៀងរាល់ឆ្នាំពិធីហាឡូវីុនជាពិធីរំលឹកដល់បុព្វការីជនដែលបានស្លាប់ទៅហើយ គេបានឆ្លាក់ផ្លែល្ពៅជាទំរុងមុខរបស់អ្នកស្លាប់ គេបានរៀបចំម្ហូបបួស ដើម្បីថ្វាយរំលឹកដល់អ្នកដែលបានស្លាប់ទៅ ។

រីឯទីបញ្ចុះសព (Cemtery)នៅឡូវែលនោះវិញបានរៀបចំកម្មវិធីឱ្យអ្នកទេសចរណ៍ធ្វើទស្សនៈកិច្ចនាសប្តាហ៍មុនក្នុងនោះមានអ្នកពន្យល់ប្រវត្តិសាស្ត្រ គឺលោក Richard P.Howe. Jr. រីឆាត ភី ហូវ ចេអ ។ លោកបាននាំភ្ញៀវទេសចរណ៍ទៅមើលផ្នូរបុរាណជាច្រើន រួចគេបានធ្វើសេចក្តីអធិប្បាយអំពីប្រវត្តិរបស់បុគ្គលនៅក្នុងផ្នូរនោះ **តទៅទំព័រទី១៧**



# ថ្នាលបណ្តុះពូជកីឡាទាត់បាល់

**ដោយ : ខ្មែរផុសស.រ.អា.**

ឡូវែលៈរៀងរាល់ថ្ងៃសៅរ៍នៅសួនឧទ្យាន "អេដវិឌ"ក្បែរវិហារសហគមន៍ឥណ្ឌាមានព្រឹត្តិការណ៍កីឡាបាល់ទាត់កុមារបានកើតឡើងជាច្រើនឆ្នាំមកហើយនៅទីនោះ។ កុមារពីអាយុ២ឆ្នាំរហូត





ដល់១៥ឆ្នាំ រាប់រយនាក់បានចូលមកហាត់កីឡាបាល់ទាត់ជាក្រុមជាពួកដឹកនាំដោយសហព័ន្ធមិនថាស្រី ឬប្រុសទេ ដូចជាគេទៅពិធីបុណ្យភ្ជុំបិណ្ឌនៅសួន"អេដវ៉ដ"ដែលក្នុងនោះមានលានប្រកួតបាល់ធំ ៤-៥ សម្រាប់កុមារ។

រួមទាំងឪពុកម្តាយដែលនាំកូនចៅមកលេងសួនកីឡាផង ព្រឹកថ្ងៃសៅរ៍ទី១៣នេះ មនុស្សមានអ៊ូអរជាប្រពៃណីដ៏អស្ចារ្យមួយដែលគ្រួសារអ្នកស្រុកឡូវែលបង្ហាញថា គាត់ព្យាយាមហាត់ពត់លត់ដៃកូនចៅរបស់ខ្លួនប្រាថ្នាឱ្យទៅជាគំពូលមនុស្សនៅអនាគតតាំងពីតូចក្រូចឆ្មាក្នុងនោះក៏មានកូនចៅអាស៊ីខ្លះដែរ។

កីឡាបាល់ទាត់ជាពពួកកីឡាដែលថ្មីសម្រាប់សហរដ្ឋអាមេរិកគេហៅថា"សកក័រ"មានអាយុប្រមាណជា២០ឆ្នាំ ចុងក្រោយនេះសោះកីឡាបាល់ទាត់អាមេរិកាំងបានចូលទៅក្នុងចំណោមនៃប្រទេសល្បីល្បាញនឹងគេទៅហើយ។ក្រុមស្ត្រីជាពិសេសក៏មានការលូតលាស់ក៏រីតពានមាសដែរ។ នាំមកពិអាស៊ីនឹងអាមេរិកឡាទីនកីឡាបាល់ទាត់នេះរៀបរាងឡើងតម្រូវនឹងជនជាតិភាគតិចដ៏ច្រើនដែលបានមកតាំងទីរស់នៅសហរដ្ឋអាមេរិកនេះរីឯនៅក្នុងសួន"អេដវ៉ដ"ថ្ងៃនេះមានមុខជាជន

តទៅទំព័រទី ១៨


FRED
BAHOU
Independent for
State Representative
67




FAMILY
Adam, Madeline, Fred, Jacob and youngest Sam

**Fred Will Focus on:**

- Our Community
- Small Business Growth
- Education
- Safety



# ហ្វេយ៍មឹកខេប ផ្ទះសម្រាប់ពិធីបុណ្យសព
# Fay McCabe Funeral Home

105 Moore Street. Lowell, MA 01852

**978-459-9222**

**បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស និងការគោរពជាង៣០ឆ្នាំមកហើយ**

- Serving All Faiths — បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals — កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services — មានផ្តល់សេវាបូជាសព
- Pre Arranged Funerals — រៀបចំរោងមុនកម្មវិធីបុណ្យសព



Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.

ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក ចន្លោះផ្លូវ Gorham St. & Lawrence St.

***លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់ និងការបម្រើល្អប្រពៃពីទីនេះ ។***

www.faymccabe.com

***មានបុគ្គលិកនិយាយភាសាខ្មែរ***

# វិស្សមកាលចុងរដូវក្តៅនៅរ៉ូដអាឡិន "ភាគ២"

**ដោយ : ពិន សំខុន**

ព្រឹកថ្ងៃសៅរ៍ ទី២៩ ស្រស់ស្រូបរួចហើយ យើងចេញដំណើរទៅកាន់ឱទ្យាន Roger William Park ដែលសួនសត្វដ៏ធំមួយស្ថិតនៅប្រមាណ១០នាទីពីផ្ទះដែលយើងសំណាក់សោះ ហើយនៅចំកណ្តាលក្រុងប្រូវីដិនថែមទៀត។ ជាសំណាងណាស់ដែលធាតុអាកាសក៏ក្តៅល្មមគ្មានភ្លៀង មេឃក៏ស្រឡះ ធ្វើឱ្យដំណើរយើងរីករាយងាយស្រួលមិននឿយហត់ឡើយ។ សំណាងមួយទៀត យើងមានអ្នកម្ចាស់ស្រុក ថានលី ជាអ្នកជូនដំណើរ ហើយដែលពិសេសទៅទៀតនោះ សូបិន ខានបានដើរលេងជាមួយឪពុកបង្កើតរបស់ខ្លួនលោក ថាច់ វណ្ណា និងជាជីតារបស់ ប៉ុណ្ណារ៉ូ ជាលើកដំបូងតាំងពីខ្លួនចូលមហាវិទ្យាល័យ រហូតមកដល់ពេលនេះ មានច្រើនឆ្នាំណាស់មកហើយ។



មនុស្សម្នាមិនច្រើនពេកទេ ដែលមកទស្សនាសួនសត្វនាថ្ងៃនេះ ដូច្នេះ ថានលី បានប៉ាន់ស្មានថាដើរមួយជុំក្នុងល្បឿនធម្មតា តាមគំនូសដែលគ្រោងឱ្យភ្ញៀវនិងប្រើពេល២-៣ម៉ោងដែរ។ យើងបានទិញសំបុត្រចូលមើលសត្វពីមួយទៅមួយ ដែលសត្វនិមួយៗមានការថែទាំសង់ជាកន្លែងរស់នៅជាធម្មជាតិរបស់វា ផ្តត់ផ្គង់ចំណីអាហារតាមឯកទេស ចិញ្ចឹមសត្វព្រៃអ្នកដែលទទួលផលរីករាយជាងគេនោះគឺ ប៉ូណ្ណារ៉ូ ដែលរំលឹកពីសត្វដែលខ្លួនបានស្គាល់តាមការអានសៀវភៅក្តីតាមខ្សែភាពយន្តក្តី ធ្វើឱ្យគេនិយាយប៉ប៉ាច់មិនចេះចប់តាមផ្លូវដ៏វែងរបស់ខ្លួនដោយគ្មានហត់នឿយនឹងភ្លេចទាំងដេកថ្ងៃត្រង់ទៀតផង។





សត្វ "ជីរ៉ាហ្វ" កវែងធំហើយខ្ពស់ឱនក្បាលមកជិត ប៉ុណ្ណារ៉ូ ធ្វើមាត់ជីបអូចយ៉ាងស្លូតបូត គួរឱ្យស្រឡាញ់ក្រៃលែង... មិនឆ្ងាយប៉ុន្មានមានសត្វសេះបង្កង់ទំហំប៉ុនសេះធម្មតាតែខ្លួនមានក្រឡាបង្កង់មិនដែលឃើញគេយកទៅផ្សាំងដើម្បីប្រើប្រាស់ជាជំនិះដូចសេះធម្មតាទេ...នៅឆ្ងាយបន្តិច សត្វគោព្រៃ "ប៊ីសហុង" ធំប៉ុនក្របី កក្រាស់រស់នៅតំបន់ជើងភ្នំធ្លាប់ជាសត្វមានប្រយោជន៍ចិញ្ចឹមពួក **តទៅទំព័រទី ០៦**



CONWAY
INSURANCE AGENCY

**រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។**

**យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :**

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វីកខឹមខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

ឱសថស្ថាន ស៊ីសាយដ៍
SEASIDE PHARMACY
169 Shirley Ave Revere, MA
(781) 284-6525




- និយាយដោយផ្ទាល់ទៅកាន់ឱសថការី
- បញ្ជូនដល់គេហដ្ឋានបើចាំបាច់
- ទទួលប័ណ្ណធានារ៉ាប់រងម៉ាស់ហេវ្វល និងប័ណ្ណធានារ៉ាប់រងផ្សេងទៀត
- អាចបន្ថែមឡើងវិញនូវវេជ្ជបញ្ជាទាំងអស់ក្នុងពេលតែមួយ
- ផលិតផលនិងសម្ភារៈមាននៅបញ្ជរតាំង
- ងាយស្រួលបញ្ជូន សូមនាំយកនូវដបថ្នាំរបស់លោកអ្នក យើងខ្ញុំជួយចាត់ចែងឱ្យ



**ផ្ទេរនូវវេជ្ជបញ្ជារបស់លោកអ្នក ហើយទទួលបាននូវវីតាមីនមួយកំប៉ុងជារៀងរាល់ខែ**

តមកពីទំព័រទី ០១ បទសម្ភាសន៏ជាមួយតំណាងរាស្ត្រខ្មែរ....

បន្តដំណើរទៅក្រុងផែនស៊ីវេនា។ លោកបានផ្តល់បទសម្ភាសន៏មួយដល់ខ្មែរផុសដែលមានខ្លឹមសារដូចតទៅ :

**សំនួរ:** កិច្ចចរចារជាមួយគណបក្សប្រជាជនកន្លងមកច្រើនតែមិនទៀងតើលោកជឿថាកិច្ចព្រមព្រៀងលើកនេះរវាងគណបក្សប្រជាជននឹងសង្គ្រោះជាតិនោះអាចរស់នៅបានវែងឆ្ងាយប៉ុណ្ណា?

**ប៉ុល ហំ:** មកទល់ថ្ងៃនេះការអនុវត្តន៏កិច្ចព្រមព្រៀងនៅមិនទាន់ប៉ះពាល់នៅឡើយទេ

ថ្វីត្បិតមានព្រឹត្តិការណ៏មិនបោះឆ្នោតឱ្យលោកស្រី មូរ សុខហួរ នឹងលោក យឹម សុវណ្ណ



ក៏ដោយ ក៏នៅតែទៅមុខពីព្រោះយើងមិនចង់ឱ្យការអនុម័តច្បាប់បោះឆ្នោតមានការរាំងស្ទះ លោក ប៉ែន បញ្ញា ប្រធានគណកម្មការនិតិកម្មបានសន្យាហើយថា របៀបវារៈកែប្រែច្បាប់បោះឆ្នោតនឹងចូលដល់សន្និបាទសភានៅដើមខែតុលានេះហើយយើងចាំមើលតទៅទៀតមកទល់ពេលនេះកិច្ចព្រមព្រៀងនៅតែមានប្រសិទ្ធភាពនៅឡើយ ។

**សំនួរ:**លោកថា ច្បាប់បោះឆ្នោតនឹងចូលដល់សភា តើគណកម្មការបានជជែកគ្នាគ្រប់ជ្រុងជ្រោយហើយ ឬនៅ?

**ប៉ុល ហំ:** ជាគោលការណ៏គណបក្សទាំង២នៅសភាព្រមព្រៀងគ្នាហើយថា ធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញពីរូបមន្ត គ.ជ.ប.៤+៤+១ហ្នឹងដូច្នេះត្រូវធ្វើច្បាប់បោះឆ្នោតថ្មីហ្នឹងឱ្យហើយមុននឹងធ្វើវិសោធណកម្មរដ្ឋធម្មនិញ្ញហ្នឹង។

**សំនួរ:** តើសភាពេញអន្តពិភក្សាគ្នាហោះយឬនៅ?

**ប៉ុល ហំ:** ជាគោលការណ៏ត្រូវមានពិភាក្សាគ្នានៅសភាពេញអង្គតែដោយច្បាប់នេះបានយល់ស្របគ្នាដោយកិច្ចព្រមព្រៀងនៅក្នុងគណកម្មការរួចហើយនឹងមិនមានពិភាក្សាអ្វីទៀតទេ នៅកិច្ចប្រជុំសភាថ្ងៃ១២តុលាខាងមុខនោះ

**សំនួរ:** តើគណបក្សប្រជាជនយល់ថាវិសោធនកម្មនេះជាផលចំណេញដល់គណបក្សខ្លួនដែរឬទេ ?

**ប៉ុល ហំ :** ខ្ញុំមិនដឹងថា គណបក្សប្រជាជនគេយល់យ៉ាងណាទេតែគណបក្សសង្គ្រោះជាតិយល់ថានេះជាផលចំណេញដល់ប្រជាជាតិពីព្រោះនេះជាគោលការណ៏លទ្ធិប្រជាធិបតេយ្យហើយ ប៉ុន្តែបើគណបក្សប្រជាជនជឿលើលិទ្ធិប្រជាធិបតេយ្យហើយអាហ្នឹងវាចំណេញដល់គាត់ហើយតែបើគាត់នៅតែចង់លួចសន្លឹកឆ្នោតដូចពេលមុនៗទេអានុះមិនចំណេញដលគាត់ទេ

**សំនួរ:**ជាទូទៅគណបក្សប្រជាជនដឹកនាំដោយហ៊ុនសែននឹងមិនធ្វើទេអ្វីខ្មែលនាំឱ្យគេខាតឬនាំឱ្យគ្រោះថ្នាក់ដល់គណបក្សខ្លួនឯងទេ តើអ្វីទៅដែលនាំឱ្យគណបក្សប្រជាជនយល់ព្រមធ្វើកិច្ចព្រមព្រាងហ្នឹង?

**ប៉ុល ហំ:** តាមទស្សនះខ្ញុំត្រូវគិតថា បើគណបក្សប្រជាជនមិនព្រមទៅវិញនឹងមានបញ្ហា

តទៅទំព័រទី ០៨

Khmer Owned & Operated

The Joint Commission National Quality Approval

Independence Home Care
Health Services LLC

ថែរក្សារសុខភាពដល់លំនៅដ្ឋានរបស់អ្នកទូរទាំងរដ្ឋ

**Licensed Home Care Provider / Companion Services**

Certified Medicare/Medicaid • Joint Commission Accreditation • Home Nursing Care Provider Licensed by RI Department of Health

**Approved Provider of All State Programs:** Department of Elderly Affairs / Department of Human Services

**Skilled Nursing**
- Registered Nurses
- Home Health Aide
- Physical Therapy
- Occupational Therapy
- Speech Therapy
- Medical Social Worker

**Unskilled Nursing**
- Companionship
- Personal Care
- Bathing
- Dressing
- Safety
- Meal Preparation and Housekeeping
- Medication Reminders
- Errands and Assistance with Transportation

**Employment**
**Nurses & CNAs**
- Helping Over 100 Rhode Island Elderly Southeast Asians
- We Employ Over 50 Southeast Asians
- FREE ASSESMENT




*Let our family, take care of yours.*



**CALL US TODAY!**
**(401) 437-8337**
www.independencehs.com
Available 24/7

1179 Elmwood Ave.
Providence, RI 02907

- See our Khmer Video about Home Care at our website -

តមកទំព័រទី ០៤
## វិស្សមកាលចុងរដូវក្តៅនៅរ៉ូដអាយឡិន

ស្បែកក្រហមច្រើនសតវត្សមកហើយ ។ គេអាចចូលទៅមើលសត្វស្លាប ដូចជាសត្វ ឥន្ទ្រីយ៍ សត្វខ្លែង សត្វទីទុយ ដែលមានដាក់សំណាញ់ជាទ្រុងធំៗរៀបចំឱ្យសត្វស្លាបទាំងនោះអាចហោះហើរបាន។ នៅមានសត្វពស់ច្រើនភេទច្រើនធុន ដែលរៀបជាក្រឡៀតក្រំថ្ម ឬកាច់សំបុកជារបៀបរស់នៅធម្មតារបស់សត្វអស់ទាំងនោះ ។ នៅមានខ្លា ស្វា ចចក ឆ្កែព្រៃ ឆ្កែរស់តំបន់ទឹកកកច្រើនលាក់ខ្លួនបាំងដើមឈើពិបាកនឹងរកមើលឱ្យឃើញបន្តិច ។ សត្វទាំងអស់សុទ្ធតែមានផ្លាកសរសេរណែនាំធ្វើឱ្យយើងងាយសំគាល់នឹងចងចាំហើយទោះជាមានចំនួនច្រើនក៏ដោយយើងឃើញអ្នកថែទាំផ្ទាល់ខ្លួនសត្វនិមួយៗប្រកបដោយការប្រុងប្រយ័ត្នខ្ពស់។





នៅចន្លោះពេលទស្សនាដើរឡើងចុះទួលឱ្យដូចជានៅក្នុងព្រៃយើងទៅដល់កន្លែងសម្រាកកាយនៅទីនោះយើងអាចរកទិញវត្ថុអនុស្សាវរីយ៍ ឬទិញភេសជ្ជៈផឹកបំបាត់សម្រេកនឹងម្ហូបស្រស់ស្រូបបំបាត់ឃ្លានទីនោះបានទៀតផង។



នៅមានទីលានសម្រាប់លេងកំសាន្ត ដូចជាកីឡាឡើងភ្នំដែល ប៉ុណ្ណារ៉ូ ចូលចិត្តចង់ឈ្នះគេណាស់ តែមិនដែលបានប្រកួតម្តងណាទេ ដោយឪពុកម្តាយពេលនោះ មិនទុកចិត្តថា ក្មេងពេកមិនអាចឡើងភ្នំបានទេ... ឥឡូវដល់ឃើញភ្នំក៏ទាបដែរ ហើយមានការប្រុងសន្តិសុខគ្រប់គ្រាន់ ហើយកូនក៏ធំណាស់ហើយយើងបានឱ្យគេរៀបចំខ្លួនប៉ុណ្ណារ៉ូ ចងខ្សែក្រវ៉ាត់ការពារកុំឱ្យធ្លាក់អ្នកបង្ហាប់បានឱ្យដំបូន្មានពីដំណើរការណ៍នឹងការប្រុងប្រយ័ត្នសម្រាប់រៀបឡើងភ្នំមែនទែន ។





យើងបញ្ចប់ដំណើរទៅសួនសត្វនៅវត្តឡើងភ្នំនេះចេញមកវិញរីករាយដោយបានឃើញសត្វប្លែកៗជីវិតរបស់ពួកគេការរៀបចំថែរសម្បត្តិធម្មជាតិ ជាពិសេសស្ញើចសរសើដល់ស្មារតីបង្ហាត់បង្រៀនជីវិតនៅជុំវិញខ្លួនយើងដល់អ្នកដទៃ។

ស្អែកឡើងយើងរៀបចំខ្លួនប្រាណទៅតំបន់មួយទៀត គឺ"ញូភ័ត" ដែលជាកំពុងផែកំសាន្តមួយនាចុងកោះ នៅផ្នែកខាងកើតនៃរដ្ឋ រ៉ូដអាយឡិន។ យើងបានទៅសំណាក់នៅសណ្ឋាគារគ្រួសារមួយដែលស្ថិតនៅ"ឃីងថោន"ដែលស្ថិតនៅចម្ងាយកន្លះម៉ោងពីទីដែលយើងត្រូវទៅកំសាន្ត ៣-៤កន្លែង ខុសៗគ្នាក្នុងតំបន់តែមួយ ។

យើងនឹងបន្តការពីពត៌នាពីតំបន់ទេសចរដ៏សំខាន់មួយទៀតនេះ គឺ"ញូភ័ត" នឹងប្រវត្តដ៏រុងរឿងនៃតំបន់នេះនៅលេខក្រោយទៀត ៕






# វិភាគលទ្ធផលនៃការបោះឆ្នោតថ្ងៃទី៩កញ្ញា







**ដោយខ្មែរផុស ស.រ.អា**

ម៉ោង៩យប់ នាថ្ងៃទី៩កញ្ញា២០១៤ លទ្ធផលធ្លាក់មកបន្តរបន្ទាប់អ្នកចាញ់នឹងអ្នកឈ្នះបានចេញមកបង្ហាញមុខអរគុណដល់ពលរដ្ឋដែលបានចេញមកបោះឆ្នោតជាទូទៅខាងគណបក្សនិមួយៗ នាជុំទីមួយនេះអ្នកចាញ់ឆ្នោតតែងអញ្ជើញអ្នកគាំទ្រខ្លួនឱ្យបង្វែរការគាំទ្ររបស់ខ្លួនទៅឱ្យអ្នកដែលឈ្នះឆ្នោតឆ្នោតទៅវិញ ពីព្រោះថានៅក្នុងការបោះឆ្នោតជុំបន្ទាប់ គឺនៅថ្ងៃទី៤ វិច្ឆិកា គឺជាការប្រមូលកម្លាំងបោះឆ្នោតតទល់រវាងគណបក្សខុសគ្នាដូចជាគណបក្សប្រជាធិបតេយ្យតទល់នឹងគណបក្សសាធារណរដ្ឋជាដើម។

បន្ទាប់ពីបោះឆ្នោតហើយភ្លាមយើងបានសុំអត្ថាធិប្បាយពីលោកផលរដ្ឋាយ៉ែមលោកបាននិយាយថា :

**ផលរដ្ឋា យ៉ែម:** ខ្ញុំមិនបានឈ្នះឆ្នោតទេ ខ្ញុំបានទៅសំដែងការកោតសសើរដល់ជ័យជំនះ រ៉ាឌី ម៉ម ហើយជូនពរឱ្យបានជោគជ័យខ្ញុំបានបន្ថែមថា បើត្រូវការឱ្យខ្ញុំជួយអ្វីខ្ញុំនឹងខំជួយឱ្យអស់ពីសមត្ថភាព។ លទ្ធផលដែលខ្ញុំទទួលឃើញថា ប្រជាពលរដ្ឋមិនចូលចិត្តទៅបោះឆ្នោតទេ ហើយខ្ញុំក៏ដឹងដែរថាឱ្យគេបោះឆ្នោតប្រើ stickers ជាការលំបាកមួយតែខ្ញុំត្រូវចូលរួមការបោះឆ្នោតរហូតដល់ចប់ ពីព្រោះខ្ញុំមិនចូលចិត្តជឿតាមការឱ្យយោបល់ទេតថែង់ពិបិសោធន៍ដោយខ្លួនឯង។ ខ្ញុំយល់ថាអ្នកបោះឆ្នោតខ្មែរច្រើនបោះឆ្នោតឱ្យបុគ្គល គឺអ្នកស្គាល់គ្នាមិនបានស្តាប់សារនៃបេក្ខជនទេ តែក៏មានស្តាប់ការពិភាក្សានឹងទទួលសារតិចតួចណាស់ ខ្លះនៅចាំពាក្យខ្ញុំនិយាយពីបញ្ហាអន្តោប្រវេសន៍ពីកាងារធ្វើពីបញ្ហាអប់រំដែរ... ចំណែកឯក្រុមស្បែកសគេបច្បាស់ជាបោះឆ្នោតឱ្យសាសន៍សគ្នាគេហើយ ។

នៅ១សប្តាហ៍បន្ទាប់ពីបោះឆ្នោតហើយលោក រ៉ាឌី ម៉ម បាននិយាយថា :

**រ៉ាឌី ម៉ម:** ខ្ញុំសូមថ្លែងអំណរគុណដល់បងប្អូនទាំងអស់ដែលបានគាំទ្រ ហើយបោះឆ្នោតឱ្យខ្ញុំ ហើយក៏ អរគុណខ្មែរផុស ស.រ.អា ផងដែរ ដែលបានខិតខំផ្តល់ព័តិមាននឹងអំពាវនាវឱ្យខ្មែរចេញទៅបោះឆ្នោត។ ថ្វីត្បិតតែអ្នកចេញទៅបោះឆ្នោតបានតិចមែនក្តីតែឆ្នោតរបស់ខ្ញុំបង្ហាញថា ខ្ញុំឈ្នះឆ្នោតនៅមណ្ឌល៦កន្លែងហើយចាញ់តែមណ្ឌល ៨-៣ មួយទេ ដែលជាតំបន់មិនសូវមានខ្មែរ។ តែខ្ញុំសង្ឃឹមយ៉ាងមាំថា បងប្អូននឹងចេញទៅបោះឆ្នោតបានច្រើនជាងពេលនេះ នៅថ្ងៃទី៤ វិច្ឆិកាខាងមុខ។ លោក ផល រដ្ឋាយ៉ែម ជាបេក្ខជនខ្មែរដែលចាញ់ឆ្នោតបានសម្តែងការគាំទ្រដល់រូបខ្ញុំវិញរួចហើយ ថែមទាំងថា នឹងជួយដល់ការឃោសនាខ្ញុំទៀតផង។ កាលពីបោះឆ្នោតរួចហើយនេះខ្ញុំឃើញថា សម្លេងក្រុម "អបព័រហាយឡិន" បានផ្ទុំទៅឱ្យ ជឹម នឹង ដូណូ វ៉ាន់ ច្រើនខ្ញុំសង្ឃឹមថា នៅលើកទីបញ្ចប់នេះក្រុមគណបក្សប្រជាធិបតេយ្យនៃ"អបព័រហាយឡិន"នឹងបោះឆ្នោតឱ្យខ្ញុំខ្លះថែមទៀត...យ៉ាងណាមិញខ្ញុំទទួលបាននូវការគាំទ្រថ្មីៗទៀតហើយមានព្រឹទ្ធសមាជិកសុងគ្លាស មានដាណាហ្យូ មាន ថម គ្លោលដិន មាន ប៉ាត្រីក ឱយវល ដែលនឹងផ្តល់ឋាមពលថ្មីដល់ការឃោសនារបស់ខ្ញុំ។ ចំណែកខាងក្រុមសាធារណរដ្ឋវិញ ខ្ញុំមិនទាន់មានការការខិតចូលជិតណាមួយនៅឡើយទេហើយខ្ញុំក៏មិនដឹងថាគេនឹងប្រកាន់យកអ្នកឯករាជ្យ ឬក៏យកខ្ញុំនៅឡើយទេ។

ការឈ្នះឆ្នោតរបស់ រ៉ាឌី ម៉ម ពេលនេះនឹងនាំឱ្យបេក្ខជនគណបក្សប្រជាធិបតេយ្យរូបនេះទៅជួបប្រកួតនឹងបេក្ខជនគ្មានគណបក្សហ្វ្រេតបាហ៊្វូ នៅឱកាសបោះឆ្នោតថ្ងៃទី៤វិច្ឆិកា ។ យោងតាមការបែកសន្លឹកឆ្នោតកាលពីជុំបឋមខាងខ្មែរ បើមានតែម្នាក់ឈរឈ្មោះអាចទទួលបានប្រមាន ៨០០សម្លេងទល់នឹងឆ្នោតសាសន៍ដទៃរួមគ្នាប្រមាន១៤០០សម្លេងក៏ប៉ុន្តែឆ្នោតបាហ៊្វូដែលមិនមែនជាគណបក្សសាធារណរដ្ឋឬប្រជាធិបតេយ្យអាចនឹងបែកសន្លឹកឆ្នោតរបស់ខ្លួនឱ្យជាប្រយោជន៍ដល់ រ៉ាឌីបាន៕

GREATER LOWELL
CHAMBER OF COMMERCE
131 Merrimack Street – Lowell MA
978-459-8154
www.greaterlowellchamber.org

A resource for your business or organization!
Networking Events
Seminars
Resources
TV & Radio Shows
And more!

សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក
ព្រឹត្តិការណ៍ទំនាក់ទំនង
សន្និសីទ
រកធនធាន
កម្មវិធីទូរទស្សន៍ និងវិទ្យុ
និងនៅមានច្រើនទៀត

នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៤ និងមានតាំងពិពណ៌ពាណិជ្ជកម្ម និងបង្ហាញផលិតផលនៅសណ្ឋាគារ ប៉ឌីសាន់ នៅឆែបហ្វត។
Save the Date: Business Expo & Showcase on October 28th at the Radisson Hotel & Suites in Chelmsford.



តមកពីទំព័រទី ០៩ បទសម្ភាសន៍ជាមួយតំណាងរាស្ត្រខ្មែរ....

អ្វីខ្លះដល់ការគ្រប់គ្រងរបស់គាត់? គឺយើងនៅតែមិនចូលសភាទាមទារដោយអហឹង្សាឱ្យមានការផ្លាស់ប្តូរ ម្យ៉ាងទៀតសហគមន៍អន្តរជាតិគេមិនទទួលស្គាល់រដ្ឋាភិបាលដែលគ្មានសភាត្រឹមត្រូវតែទាមទារឱ្យពិនិត្យសន្លឹកឆ្នោតឡើងវិញរដ្ឋាភិបាលនៅគាំងដំណើរនេះជាហេតុធំទាំងយើងទាំងសហគមន៍អន្តរជាតិចង់បានបើមិនបានថ្ងៃនេះទេ គឺឱ្យមានការរៀបចំកែរប្រែសង្គមប្រជាធិបតេយ្យឱ្យបានទៅថ្ងៃមុនបើមិនត្រៀមធ្វើទេយើងនៅតែទាមទារធ្វើឱ្យគាត់ទាល់ច្រកដោយអស្តេរភាពនយោបាយរហូតទាល់តែបាន

**សំនួរ:** ច្បាប់បោះឆ្នោតនឹងដូរហើយគណកម្មការសភាក៏រៀបរួចហើយដែរតើលោកនៅតែសង្ឃឹមថា គណបក្សសង្គ្រោះជាតិនៅតែបានសន្លឹកឆ្នោតភាគច្រើនលើសលប់ដដែលឬយ៉ាងណា?

**ប៉ុល ហំ:** នេះអាស្រ័យដោយការងាររបស់យើងបើពលរដ្ឋឃើញថាយើងប្រឹងប្រែងធ្វើការ



ជូនជាតិគេនឹងបោះឆ្នោតឱ្យយើងម្តងទៀតបើយើងគ្មានមាយាទទេនោះគេនឹងមិនបោះឆ្នោតឱ្យទេ□ យើងថា ប្រឹងប្រែងនេះមិនមែនបានន័យថា យើងសន្យាថា ធ្វើបានទាំងអស់នោះទេពីព្រោះយើងមិនទាន់កាន់អំណាច ក៏ប៉ុន្តែយើងមានបីឆ្នាំកន្លះសម្រាប់រៀបចំពង្រឹងគណកម្មការសភារបស់គណបក្សសង្គ្រោះជាតិ យើងមាន៥រួចហើយ យើងបង្កើតគណកម្មការ ទន្ទឹមសភាហ្នឹង៥ទៀតសម្រាប់តាមដានដូចជាយើងមានគណកម្មការ ១០អីចឹងសម្រាប់ជួយកាងារយើងជាមួយអង្គការក្រៅរដ្ឋាភិបាលដែលគេមានពតិមានលំអិតពីគ្រប់វិស័យទាំងអស់ ។

**សំនួរ:** ឱប្បមាថា ដល់ពេលបោះឆ្នោតខាងមុខគណបក្សសង្គ្រោះជាតិឈ្នះឆ្នោតតើអ្វីទៅដែលធ្វើឱ្យលោកជឿថា គណបក្សប្រជាជននឹងសុខចិត្តចាញ់ ហើយប្រគល់អំណាចឱ្យអ្នកដែលឈ្នះ?

**ប៉ុលហំ:** ទី១ យើងធ្វើឱ្យមានការប្រកាសជាផ្លូវការថាយើងឈ្នះមែនគណបក្សប្រកែកមិនបានទេ ពីព្រោះគ.ជ.ប.នៅក្នុងកិច្ចព្រមព្រាងរបស់គាតដែរ ទី២លោក សម រង្ស៊ី បាននិយាយនៅក្នុងសភាថា កុំឱ្យមានការសងសឹកគ្នាពេល ជាប់ឆ្នោតដូចទឹកឡើងត្រីស៊ីស្រមោចតីហោចស្រមោចស៊ីត្រី

**សំនួរ :** សូមអរគុណ

# បទសម្ភាសន៍ជាមួយតំណាងរាស្ត្រខ្មែរឯកឧត្តម វ៉ា សាមឿន

**ដោយ :ពិន សំខុន**

លោក វ៉ា សាមឿន ជាតំណាងរាស្ត្រខេត្តកំពតនៅក្នុងគណកម្មការសភាជាតិទី៣ ទទួលបន្ទុកខាងបរិដ្ឋាននឹងកសិកម្មសមាជិកគណបក្សសង្គ្រោះជាតិមានទីលំនៅនៅ"ស៊ីអាថល"សហរដ្ឋអាមេរិក **តទៅទំព័រទី ០៩**



តមកទំព័រទី ៨ បទសម្ភាសន៍ជាមួយតំណាងរាស្ត្រខ្មែរ...

លោកចូលរួមដំណើរទស្សនកិច្ចមកក្រុងឡូវែលជាមួយនឹងលោក ប៉ុល ហំ ថ្ងៃ១៤កញ្ញា ២០១៤ ដែរ ។

**សំនួរ:** បងប្អូនខ្មែរយើងជាច្រើនមានចម្ងល់ថា ដូចរូបលោកបានរស់នៅសុខស្រួលនៅសហរដ្ឋអាមេរិក ហើយយល់យ៉ាងណាដែរ ដែលសម្រេចចិត្តត្រឡប់ទៅធ្វើការនៅប្រទេសកម្ពុជាវិញ?

**វ៉ាសាមឿនៈ** ខ្ញុំបានមករស់នៅសហរដ្ឋអាមេរិកនេះ៣៣ឆ្នាំធ្វើការនៅ "កុំផានីប៊ូអ៊ីង" ចំនួន២៥ឆ្នាំ នៅពេលដែលខ្ញុំធ្វើការខ្ញុំតែងតែគិតដល់កម្ពុជាចេះតែចោទសួរថាហេតុអ្វីក៏សហរដ្ឋអាមេរិកគេដឹកនាំបានប្រសើរហើយខ្មែរយើងដឹកនាំមិនកើតសោះនៅអាមេរិកនេះគេមានប្រធានអនុប្រធានហើយគេមានជំនាញការគេគ្រប់ផ្នែកដែលជួយធ្វើការគេហើយខ្ញុំចង់ជួយខ្មែររបៀបហ្នឹងខ្ញុំបានត្រឡប់ទៅកម្ពុជាវិញ នៅឆ្នាំ២០១២ ពេលខ្ញុំចូលនិវត្តន៍ហើយបងប្អូនខ្មែរដែលខ្ញុំបានជួបក៏ចូលចិត្តឃើញខ្មែរទៅពីបរទេសត្រឡប់ទៅជួយកម្ពុជាវិញដែរដោយគេឃើញខ្ញុំធ្វើការគេថាខ្មែរនៅឯណោះចេះយកចិត្តទុកដាក់ពីខ្មែរចេះស្រឡាញខ្មែរពិតប្រាកដ ។


ខ្មែរផុសសម្ភាសន៍ជាមួយ ឯកឧត្តម វ៉ា សាមឿន

**សំនួរ:** នៅពេលចេញទៅឃោសនាបោះឆ្នោត តើបងប្អូនខ្មែរយើងគេនិយាយពីអ្នកទៅពីបរទេសយ៉ាងណាដែរបើខាងគណបក្សប្រជាជនគេថា ជាអណិកជនជជុះអ្នកឆាប់រត់ចោល គេ..?

**វ៉ាសាមឿនៈ** សម្រាប់ខ្ញុំមិនដែលប្រទះរឿងយ៉ាងនេះទេ ខ្ញុំមានសំណាងដែលបានធ្វើការជាមួយប្រធាន សម រង្ស៊ី នឹងអនុប្រធាន កឹម សុខា ដែលសិទ្ធតែមានបទពិសោធន៍ធ្វើការជាមួយពលរដ្ឋនឹងសកម្មជនដែលមានប្រជាប្រិយភាពយើងលើកទឹកចិត្តគ្នានឹងមានការចុះសម្រុងគ្នា

**សំនួរ:** ដល់ពេលចូលសភា តើមានអ្នកណាថាអ្នកទៅពីបរទេសទៅដណ្តើមកន្លែងអ្នកនៅក្នុងស្រុកដែរឬទេ?

**វ៉ាសាមឿនៈ** នេះជាការធម្មតាទេប្រជាពលរដ្ឋខ្លះតែងយល់ច្រឡំអ៊ីចឹង ហើយគាត់មិនដឹងថានៅពេលដាប់ប្តើមគណបក្សត្រូវការមនុស្សមានសមត្ថភាពនឹងមានលទ្ធភាពដើម្បីទៅបំរើជាតិបើយើងមានតែសមត្ថភាពតែគ្មានសមត្ថភាពក៏មិនអាចធ្វើអ្វីកើតដែរ ។

**សំនួរ:** បើមានប្រជាពលរដ្ឋយល់ច្រឡំយ៉ាងនេះតើលោកធ្វើអ្វីដើម្បីកែរតម្រូវបើគេមានលទ្ធភាពដែរតើលោកនៅតែធ្វើ ឬយ៉ាងណា?

**វ៉ាសាមឿនៈ** យើងត្រូវតែព្យាយាមអត់ធ្មត់ពន្យល់ពួកគាត់នឹងខំបង្ហាញថា យើងមកជួយជាតិជាមួយគណបក្សសង្គ្រោះជាតិបើយើងធ្វើមិនបានទេគ្រប់គ្រងពួកគាត់មិនបានទេ ៕

**ខ្មែរផុសស.រ.អា.: សូមអរគុណ**

# ហេតុអ្វីក៏ រ៉ាឌីម៉មឈ្នះឆ្នោត? Why did Rady Mom win?

**ដោយ : រីកឆឺតហាវ ជឺអរ**


Richard Howe

នៅក្នុងការបោះឆ្នោតបឋមនៃគណបក្សប្រជាធិបតេយ្យ កាលពីថ្ងៃទី៩ កញ្ញា ២០១៤ រ៉ាឌីម៉ម បានធ្វើឱ្យគេស្រឡាំងកាំងដោយឈ្នះឆ្នោតនៅសង្កាត់"មីឌុលសិក១៨" ទទួលបានឆ្នោត៦៤៧សម្លេង។ ឆ្នោតនេះឈ្នះលើ ជីម ឡេរី "បាន៥៩៥សម្លេង" លើប្រាអិន ដូណូវ៉ាន់ "បាន៥៧៦សម្លេង" ដេវ អាវឡេត"បាន៣៤៥សម្លេង" នឹង ផល រដ្ឋា យ៉ែម"បាន២៤៥សម្លេង"។

ម៉ម ឈ្នះដោយសារមានមូលដ្ឋានគាំទ្រទូលំទូលាយជាងបេក្ខជនឯទៀតៗ។ នៅមណ្ឌលបោះឆ្នោតចំនួន១២ ក្នុងសង្កាត់ ម៉ម ដឹកមុខចំនួន៦មណ្ឌល អាវឡេត ដឹកមុខបាន៣មណ្ឌល ឡេរី ដឹកមុខបាន២មណ្ឌល ហើយ ឌូណូវ៉ាន់ ដឹកមុខបាន១មណ្ឌល។ ពិនិត្យលំអិតលទ្ធផលនៃហិបឆ្នោត២ មណ្ឌល២ ម៉ម បាន៤៦សម្លេងទល់នឹង ឡេរី បានតែ១៨ -នៅហិប៧ មណ្ឌល២ ម៉ម បាន៤៤ ឡេរី បាន១៣។ បើប្រៀបធៀប ម៉ម ទៅនឹង ដូណូវ៉ាន់ នៅហិប៣ មណ្ឌល១ ម៉ម បាន៤២សម្លេងទល់នឹង ដូណូវ៉ាន់ ១៣សម្លេង រីឯនៅហិប៧ មណ្ឌល ៣ ម៉ម បាន៦២ ដូណូវ៉ាន់ បាន៥សម្លេង។ សម្លេងគាំទ្រភាគច្រើនរបស់ ឡេរី នឹង ដូណូវ៉ាន់ មកពីមណ្ឌលតែមួយគត់ គឺហិប៨ មណ្ឌល៣។ នៅក្នុងមណ្ឌលនោះ"ជាមណ្ឌលមួយក្នុងចំណោម ២នៃសាលាដាលី" ឡេរី បាន២១៩ ដូណូវ៉ាន់ បាន២០៨ ហើយនឹង ម៉ម បានតែ៨៨សម្លេង។

ឥឡូវ ម៉ម ត្រូវប្រឈមមុខនឹង ហ្វ្រេត បាហ៊ូ ជាបេក្ខជនគ្មានគណបក្ស នៅថ្ងៃទី៤ វិច្ឆិកា ឆ្នាំ ២០១៤ នៅក្នុងការបោះឆ្នោតរដ្ឋខាងមុខ។ បាហ៊ូ ជាបេក្ខជនខ្លាំងម្នាក់គាត់ធ្លាប់បំរើការក្រុងឡូវែល ជា vocational school committee election ហើយគាត់មានហាងវីនស័រស្ហុពដែលមានប្រជាប្រិយភាពជាមួយអ្នកបោះឆ្នោតនៅអាព័រហាយឡិន "ឬហាយឡិនលើ"។

នៅមានមនុស្សជាច្រើនដែលរស់នៅឡូវ័រហាយឡិន "ឬហាយឡិនក្រោម" នឹងនៅ អេគ័រ ដែលបានចុះឈ្មោះបោះឆ្នោតហើយតែមិនខ្វល់នឹងទៅបោះឆ្នោត។ សម្រាប់ រ៉ាឌីម៉ម ដើម្បីឈ្នះឆ្នោតនៅខែវិច្ឆិកានោះគាត់ត្រូវពន្យល់ឱ្យអ្នកដែលមិនដែលចូលរួមបោះឆ្នោតទាំងនោះឱ្យទៅមណ្ឌលគាត់ នាថ្ងៃបោះឆ្នោតហើយជ្រើសយក រ៉ាឌីម៉ម សម្រាប់សង្កាត់ "មីឌុលសិក១៨" ៕

**By Richard P. Howe Jr.**

In the September 9, 2014 Democratic Primary Election, Rady Mom won a stunning victory in the 18th Middlesex State Representative race by receiving just 647 votes. He defeated Jim Leary (595 votes), Brian Donovan (576), Dave Ouellette (345 votes), and Paul RathaYem (245 write in votes).

Mom won because he had the broadest base of support of all the candidates. Of the 12 voting precincts in the district, Mom came in first in 6 of them; Ouellette was first in 3; Leary was first in 2; and Donovan was first in 1. Consider that in Ward 2, Precinct 2, Mom got 46 votes to Leary's 18 and in Ward 7, Precinct 2, Mom got 44 votes to Leary's 13. Comparing Mom to Donovan, in Ward 3, Precinct 1, Mom got 42 votes to Donovan's 13 while in Ward 7, Precinct 3, Mom got 62 to Donovan's 5. The bulk of the support for both Leary and Donovan came from a single precinct, Ward 8, Precinct 3. In that precinct (which is one of two at the Daley School), Leary got 219, Donovan got 208 and Mom got 88.

Rady Mom will now face Fred Bahou, an unenrolled candidate, in the November 4, 2014 state election. Bahou is a strong candidate. He has served on the Greater Lowell Vocational School Committee elections and his store, the Windsor Shoppe, is popular with many voters in the upper Highlands.

There are many people who live in the lower Highlands and the Acre who are registered to vote but do not bother voting in elections. For Rady Mom to win in November, he must convince large numbers of the people who normally don't participate to go to their voting place on election day and to choose Rady Mom for the 18th Middlesex District.

# លទ្ធផលលើកដំបូងនៃការបោះឆ្នោតរបស់បេក្ខជនប្រចាំរដ្ឋម៉ាសាឈូសេត

**រាយការណ៍ដោយ : លោក រីឈឹត ភី ហូវ ជេអ.(Richard P.Howe Jr)**

**បកស្រាយដោយលោក : ថាច់ វណ្ណា**

កាលពីថ្ងៃអង្គារ៍ ទី០៩ កញ្ញា ២០១៤ កន្លងមកនេះប្រជារាស្រ្តនៅរដ្ឋម៉ាសាឈូសេត បានទៅបោះឆ្នោតជ្រើសរើសបេក្ខជនជាតំណាងគណបក្សប្រជាធិបយេត្យ និងគណបក្សសាធារណៈរដ្ឋ ដើម្បីនឹងចូលទៅបោះឆ្នោតជាតំណាងគ្រប់មុខក្រសួងនានា ក្នុងរដ្ឋនៅថ្ងៃទី៤ ខែវិច្ឆិកា ខាងមុខនេះ ។

*ផ្នែក អភិបាលរដ្ឋ, គណបក្សប្រជាធិបតេយ្យបានតែងតាំងលោកស្រីម៉ាថា ខកស៊ុ(Marta Coakley) អ្នកបានឈ្នះលើលោក សទីវិន ហ្គស់ ម៉ែន (Steven Gross man) និង ដូនួល បើវីក (Donald Berwick)

ផ្នែកសាធារណៈរដ្ឋ ក៏បានជ្រើសតាំងលោក ឆាស៊ុ បេក្កើ (Charlie Baker)ដែលជាអ្នកបានឈ្នះឆ្នោតលើលោក ម៉ក ភិសឿ(Mark Fisher)នៅក្នុងគណបក្សឱ្យចេញជាបេក្ខជនតទល់នឹងលោក (Coakley)មកពីគណបក្សប្រជាធិបតេយ្យ ។

*ផ្នែកខាងការិយាល័យភូឈួយវិញ គណបក្សប្រជាធិបតេយ្យបានជ្រើសតាំងលោក ស្ទេពិន ឃើរីហ្គាន (Stephen Kerrigan)ដែលបានឈ្នះឆ្នោតលើលោក លីុឡិន ឆឿន (Leland cheung) និងលោក ម៉ាយលេខ (Mike Lake)និងលោក ការ៉ិន ប៉ូលីុតូ(Karyn Polito)ឱ្យចេញជាបេក្ខជន ។

រីឯគណបក្សសាធារណៈរដ្ឋវិញ បេក្ខជនសំរាប់ភូឈួយមិនមានប្រជែងឡើយ ហេតុនេះបេក្ខជនសំរាប់ផ្នែកអភិបាល និងសំរាប់តំណែង ភូឈួយ និងត្រូវបានជ្រើសរើសលោក ខក់ ស៊ី (Coakley) និងលោក ខើរ៉ុ ហ្គាន(Kerriyan)ជាបេក្ខជនខាងគណបក្សប្រជាធិបតេយ្យ ។

ឯលោក បេក្កើ (Baker) និងលោក ប៉ូលីុតូ (Polito)ជាបេក្ខជនខាងគណបក្សសាធារណរដ្ឋ អ្នកទាំង៤ និងបានចុះឈ្មោះក្នុងបញ្ជីបេក្ខជនឈ្នះឆ្នោត សំរាប់ខែ វិច្ឆិកា ខាងមុខនេះ ។

*ផ្នែកគណៈមេធាវីវិញ គណបក្សប្រជាធិបតេយ្យលោកស្រី ម៉ូរ៉ា ហ៊ីលីុ (Maura Healey) គាត់បានឈ្នះឆ្នោតលើ វ៉ រីន ថូវម៉ែន (Warren Tolman)លោកស្រីនឹងឈរជាបេក្ខជនតទល់នឹងលោក ចន មីវឡើ (John Miller) មកពីគណបក្សសាធារណៈរដ្ឋក្នុងខែវិច្ឆិកាខាងមុខ ។

*ផ្នែករតនសម្បត្តិគណបក្សប្រជាធិបតេយ្យបានជ្រើសយកលោក ឌីប៉ូរ៉ា ហ្គលបឿក (Deborah Goldberg)ដែលបានឈ្នះឆ្នោត លើលោក បែរ៉ុ ផាញហ្គល (Barry Finegold) និងលោក ផម ខនរ៉យ (Ton Conroy)ជាបេក្ខជនឈ្នះឆ្នោតតទល់ជាមួយលោក ម៉ាយ ហិបហ្វើ ណាន់ (Mike Heffernan)មកពីគណបក្សសាធារណៈរដ្ឋ ។

*រដ្ឋអគ្គលេខាធិការលោក វៀវ លៀម ហ្គាលវិន (William Galvin) ជាគណបក្សប្រជាធិបតេយ្យលោកកំពុងកាន់តំណែងនេះ និងឈរជាបេក្ខជនតទល់នឹងលោក ដេវីុត ដាកខែនជីឡូ (David D´Arcangelo) មកគណបក្សសាធារណៈរដ្ឋ ។

*ផ្នែក រដ្ឋសាវនដ្ឋាន គណបក្សប្រជាធិបតេយ្យកំពុងកាន់តំណែងដោយ ស៊ុសានី ប៉ាម (Suzanne Bump)នឹងឈរជាបេក្ខជនទល់នឹង លោក ប៉ាត្រីកសៀ អេសធី. អប៊ីន (Patricia St.Aubin)មកគណបក្សសាធារណរដ្ឋ ។

*ការិយាល័យព្រឹទ្ធសភា ស.រ.អា នឹងយោងទៅតាមសន្លឹកឆ្នោតក្នុងខែវិច្ឆិកាខាងមុខនេះ លោក អិដ ម៉កឃីុ (Ed. Markey)ជាអ្នកត្រូវបានទទួលការបោះឆ្នោតជាពិសេសមួយក្នុងព្រឹទ្ធសភា កាលពីនិទាឃរដូវឆ្នាំ២០១៣ និងត្រូវមានការប្រកួតប្រជែងអំពីលោក ប្រៃអីន ហឿ (Brian Herr) មកពីគណបក្សសាធារណរដ្ឋ ។

ក្នុងខណៈពេលដ៏សំខាន់សំរាប់ការបោះឆ្នោតជ្រើសតាំងឱ្យទល់មុខតំណែង តើអភិបាលនិងទេសាភិបាលដែលមានឥទ្ធិពលមកលើជីវភាពរស់នៅរបស់ប្រជារាស្រ្តលោក ម៉ាថា ខកស៊ុ (Martha Coakley)មកពីគណបក្សប្រជាធិបតេយ្យ និងលោក ឆាលីុ បេក្កើ (Charlie Baker) ធ្លាប់បានធ្លាក់ឆ្នោតកាលពីឆ្នាំ២០១០ ។

ខក់ស៊ី (Coakley)បានឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភាស.រ.អា ពេលផ្ដើមបោះឆ្នោតឃើញថា អាចនឹងឈ្នះលើសន្លឹកឆ្នោតរបស់លោក ស្កត ប្រោន (Scott Brown)តែទីបំផុតបែជាចាញ់ឆ្នោតរបស់លោក ស្កត ប្រោន ទៅវិញ ។

រីឯលោក បេក្កី (Baker)វិញ បួនឆ្នាំកន្លងមកលោកបានឈរជាបេក្ខជន ទេសាភិបាល ប៉ុន្តែលោក បេក្កី បានចុះចាញ់លោក ដេវ៉ូវ ផែតត្រឹក (Daval Patrick)ក្នុងខណៈដែលកំពុងធ្វើការឃោសនាបោះឆ្នោត ក្នុងពេលនោះ ប្រជារាស្ត្រជាច្រើនមិនបានបោះឆ្នោតឱ្យលោក បេក្កើ ទេ ពីព្រោះឃើញគាត់កំពុងខឹងសំបាជាខ្លាំង ម៉្លោះ

តទៅទំព័រទី ១៧

# Primary Election Resultsfor Statewide Candidates

**By Richard P. Howe Jr.**







On Tuesday, September 9, 2014, voters across Massachusetts selected candidates to represent the Democratic and Republican Parties in the November 4, 2014 election for various statewide offices. For Governor, the Democrats nominated Martha Coakley who defeated Steven Grossman and Donald Berwick. Coakley will face the Republican nominee, Charlie Baker in November. Baker defeated Mark Fisher in the Republican Primary.

For the office of Governor, the Democrats nominated Stephen Kerrigan who defeated Leland Cheung and Mike Lake. KarynPolito, the Republican candidate for Lieutenant Governor, had no opposition. In November, candidates for Governor and Governor will run as a ticket, so voters will select Democrats Coakley and Kerrigan or Republicans Baker and Polito.

For the Democratic nomination for Attorney General, Maura Healey defeated Warren Tolman. Healey will face Republican John Miller in November. For Treasurer, Deborah Goldberg defeated Barry Finegold and Tom Conroy. Goldberg will face Republican Mike Heffernan. For Secretary of State, incumbent William Galvin, a Democrat, will face Republican David D'Arcangelo and for State Auditor, incumbent Suzanne Bump, a Democrat, will face Republican Patricia St. Aubin.

The office of U.S. Senator will also be on the ballot this November. Ed Markey, who was elected Senator in a special election in the spring of 2013, will be challenged by Republican Brian Herr.

While every elected office is important, who will be the next governor will have the biggest effect on the lives of ordinary people. Both the Democrat Martha Coakley and the Republican Charlie Baker have lost difficult elections in the past. In 2010, Coakley ran for United States Senator but lost to Scott Brown despite starting with a big lead. Baker ran for governor four years ago but lost to Deval Patrick who was running for reelection. In that campaign, many people did not vote for Baker because he seemed too angry. Now, both Coakley and Baker have learned from their mistakes and are better candidates.

The two major political parties, the Democrats and the Republicans, have very different philosophies about the role of government. In general, Democrats like Martha Coakley believe that government should help people who need it by providing more education, better health care, housing assistance and job training until the people in need are able to find good jobs and housing. Republicans, like Charlie Baker believe that government should play less of a role in people's lives; that every government program costs money and that it's better to let people and corporations keep more of their money than to have them pay it to the government in taxes even if the taxes are used to help those in need.

# ពហិការនៅផ្សារ ម៉ាក ឃីត បាសឃីតបានបញ្ចប់ហើយ

# BOYCOTT AT MARKET BASKET HAS END

**រៀបរៀងដោយ : ថាច់ វណ្ណា**

តើក្រោយពេលបាតុកម្ម៤០ថ្ងៃនៅទីផ្សារ ម៉ាកឃីត បាសឃិតនឹងមានដំណើរការយ៉ាងណានោះ? យើងខ្ញុំខ្មែរផុស ស.រ.អា. បានទៅពិនិត្យហេតុការទាំងនោះឃើញថា មានដំណើរការប្រសើរឡើងវិញហើយ។ បន្ទាប់ពីមានរឿងរ៉ាវអធិភាពនឹងពហិការរវាងលោក។ អទ័រ អេស នឹង អទ័រធី លោកទាំងពីរជាបងប្អូនជីដូនមួយបានប្រជែងគ្នា ដើម្បីក្តាប់សិទ្ធត្រួតត្រាលើទីផ្សារម៉ាតឃីត។ បាសឃិត។ ជាទីផ្សារដ៏ធំដោយមានសាខាចំនួន៧១ទីផ្សារនេះមានដើមទុនចំនន្ទួន៤ពាន់ពារយលាន ស.រ.អា លោក អទ័រ ធី គាត់ជាមនុស្សមានប្រជាប្រិយភាពស្និតស្នាលជាមួយបុគ្គលិក និងកម្មករក្នុងខណៈដែលលោកបានកាន់កាប់មុខងារប្រធានគណៈប្រតិបត្តិ (CEO) តាំងពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៣ លោកបានដាក់ថ្លៃទំនិញដោយតម្លៃយ៉ាងសមរម្យលម្មបង្គួរ រហូតដល់ខែកុម្ភៈ ឆ្នាំ ២០១៤ លោក អទ័រ អេស ក៏បានដណ្តើមសិទ្ធិកាន់កាប់(CEO)ពីលោក អទ័រ ធី ដោយវិធីបង្វិលប្រាក់ចំណេញក្នុងភាគហ៊ុនរបស់លោកមានចំនួន៤២៤លានដុល្លារ ស.រ.អា ព្រមទាំងប្រាក់ភាគហ៊ុនក្នុងក្រុមគ្រួសាររបស់គាត់បន្ថែមចំនួនពារយលានដុល្លារបន្ថែមទៀត ដើម្បីដណ្តើមសិទ្ធិគ្រប់គ្រងលើទីផ្សារម៉ាកឃីតបាសឃីត។

មកដល់ថ្ងៃទី២៧ខែកុម្ភៈ ឆ្នាំ២០១៤ លោក អទ័រ ធី ក៏បានបើកអង្គប្រជុំមួយដើម្បីធ្វើសេចក្តីសម្រេចចិត្តក្នុងរឿងនេះ ដោយមូលហេតុថ្លៃពន្ធពីរដ្ឋបានឡើងកម្រិតខ្ពស់? បណ្តាលឱ្យប្រាក់




ចំណេញមានការចុះថយទើបគណកម្មការក្រុមហ៊ុនឱ្យលោក អទ័រ ធី លាចេញពីតំណែងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤។

បន្ទាប់ពីលោក អទ័រ ធី បានឈប់សម្រាករួចហើយអ្នកថ្មីឡើងកាន់កាប់ទីផ្សារនេះ បានធ្វើ




ឱ្យប៉ះពាល់ដល់ជីវភាពបុគ្គលិក និងកម្មករ ព្រមទាំងប្រជារាស្ត្រនៅរដ្ឋម៉ាសាឈូសិតនិងនៅរដ្ឋនីវិហែមសើជាខ្លាំង ពីព្រោះគណកម្មការក្រុមហ៊ុនថ្មីនេះ បានកាត់បន្ថយបៀវត្សរ៍បុគ្គលិកកម្មករព្រមទាំងតម្លើងថ្លៃទំនិញទីផ្សារទៀតផង។

ព្រោះហេតុនេះហើយ ទើបពួកបុគ្គលិក និងកម្មកររាប់ពាន់នាក់រួមមាន៧១សាខានាំគ្នាធ្វើបាតុកម្មទាមទារឱ្យលោក អទ័រ ធី ចូលមកកាន់តំណែងដូចដើមវិញ ដើម្បីដោះស្រាយបញ្ហាថ្លៃទំនិញ និងថ្លៃបៀវត្សរ៍ឱ្យបានល្អប្រក្រតីដូចដើមវិញ ពួកកម្មករបាននិយាយបន្ថែមថា : ពួកគេធ្វើបាតុកម្មមិនមែន **តទៅទំព័រទី ២៣**






ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំពាក់ទំព្រែសរួលព័ត៌មានសារអង់គ្លេស អត្ថបទដកស្រង់ និងបកប្រែដោយមានការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សៅរ៍ ទី២០ ខែកញ្ញា ឆ្នាំ២០១៤

## ការបោះឆ្នោតលើសំណើរដាក់គ.ជ.ប.ជាស្ថាប័នធម្មនុញ្ញនឹងធ្វើនៅដើមខែតុលា

**ដោយៈ គុចណារ៉េន** | **September 12, 2014**

សមាជិកសភាមកពីគណបក្សប្រឆាំងបានឱ្យដឹងកាលពីម្សិលមិញថា រដ្ឋសភានឹងបោះឆ្នោតលើសំណើមួយដើម្បីដាក់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប.)ជាស្ថាប័នធម្មនុញ្ញនៅដើមខែតុលាជាផ្នែកមួយនៃកិច្ចព្រមព្រៀងរវាងគណបក្សប្រជាជនកម្ពុជានិងគណបក្សសង្គ្រោះជាតិកាលពីខែកក្កដាដើម្បីឱ្យគណបក្សប្រឆាំងបញ្ចប់ការធ្វើពហិការមិនចូលសភា។

គណបក្សសង្គ្រោះជាតិបានចោទប្រកាន់គណបក្សប្រជាជនកម្ពុជាថាបានលួចបន្លំសន្លឹកឆ្នោតដើម្បីឱ្យខ្លួនទទួលបានជ័យជម្នះក្នុងការបោះឆ្នោតជាតិកាលពីឆ្នាំមុនហើយបានរិះគន់យ៉ាងខ្លាំងលើគ.ជ.ប. ដែលបានជួយគណបក្សប្រជាជនកម្ពុជាឱ្យទទួលបានជ័យជម្នះនេះ។ នៅក្នុងកិច្ចព្រមព្រៀងដែលធ្វើឱ្យគណបក្សប្រឆាំងបញ្ចប់ការធ្វើពហិការមិនចូលសភានោះគណបក្សប្រជាជនកម្ពុជាកាលពីខែកក្កដាបានយល់ព្រមដាក់គ.ជ.ប.នៅក្នុងរដ្ឋធម្មនុញ្ញជាទង្វើមួយដែលគណបក្សសង្គ្រោះជាតិសង្ឃឹមថា នឹងជួយធ្វើឱ្យគ.ជ.ប.កាន់តែមានឯករាជភាព។

លោក អេង ឆៃអ៊ាង សមាជិកសភាមកពីគណបក្សសង្គ្រោះជាតិនិងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដែរនោះបានលើកឡើងថា បន្ទាប់ពីកិច្ចប្រជុំកាលពីម្សិលមិញគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាបានយល់ព្រមដាក់ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅក្នុងរបៀបវារៈនៃសម័យប្រជុំរដ្ឋសភាដែលនឹងធ្វើឡើងនៅដើមខែតុលា។

ការធ្វើវិសោធនកម្មនឹងតម្រូវឱ្យមានការកែប្រែពាក្យខ្លះនៅក្នុងមាត្រា៧៦នៃរដ្ឋធម្មនុញ្ញនិងបន្ថែមជំពូកថ្មីមួយគឺជំពូកទី១៥ ។ការអនុម័តនឹងតម្រូវឱ្យមានការបោះឆ្នោតពីសមាជិកពីរភាគបីនៃសមាជិកសភាសរុបដែលមាន១២៣រូប។

លោកឆៃអ៊ាងបានមានប្រសាសន៍ថា "គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចដាក់បញ្ហានៃការធ្វើវិសោធនកម្មមាត្រា៧៦នៃរដ្ឋធម្មនុញ្ញក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គដែលនឹងធ្វើឡើងនៅ

**តទៅទំព័រទី ១៣**

## Vote Set for Election Committee Amendment

**BY KUCH NAREN | SEPTEMBER 12, 2014**

The National Assembly will vote on a proposal to make the National Election Committee (NEC) a Constitutional body in early October, opposition lawmakers said on Thursday, honoring part of a deal the ruling CPP struck with the CNRP in July to get the opposition to end its boycott of parliament.

The CNRP had accused the CPP of cheating its way to victory in last year's national election and put much of the blame on an NEC stacked with CPP loyalists. In a deal that got the opposition to call off its boycott of parliament, the CPP agreed in July to enshrine the NEC in the Constitution, a move the CNRP hopes will help make the committee more independent.

After meeting on Thursday, the Assembly's 13-member permanent committee agreed to put the constitutional amendment on the Assembly's agenda for early October, according to CNRP lawmaker and permanent committee member EngChhayEang.

The amendment will require both changing some language in Article 76 of the Constitution and adding a new 15th chapter. Approval will require votes from two-thirds of the 123-seat Assembly.

"The permanent committee decided to put the matter of amending Article 76 of the Constitution on the upcoming plenary session agenda for early October," Mr. ChhayEang said. "We also talked about [discussing] Chapter 15…[at] the National Assembly's next session."

An exact date for the session has not yet been announced.

CNRP lawmaker YemPonhearith, who also sits on the permanent committee, said the group discussed plans to have the National

**Continued to Page 13**

## វៀតណាមនឹងធ្វើការផ្លាស់ប្តូរអ្នកនាំពាក្យស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា

**ដោយៈ ឃី សុវុឌ្ឍី** | **SEPTEMBER 12, 2014**

មន្ត្រីបាននិយាយកាលពីម្សិលមិញថា អ្នកនាំពាក្យស្ថានទូតវៀតណាមដែលពាក្យសម្តីដ៏ចម្រូងចម្រាសរបស់អ្នកនាំពាក្យរូបនេះ អំពីប្រវត្តិសាស្រ្តនៃទឹកដីកម្ពុជាក្រោមបានបង្កឱ្យមានការតវ៉ាជាតិនិយម កាលពីខែកក្កដានិងខែសីហានោះនឹងត្រូវផ្លាស់ប្តូរចេញ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាបានថ្លែងបន្ទាប់ពីជំនួបរវាង លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិលោក ផាម ក្វាងវិញ អនុរដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម និងលោក ថាច់ ឌូ (Thach Du) ឯកអគ្គរដ្ឋទូតវៀតណាមទើបតែងតាំងថ្មីថា "ស្ថានទូតវៀតណាមនឹងធ្វើកំណត់ទូតផ្ញើជូនក្រសួងការបរទេសរបស់យើងដើម្បីផ្លាស់អ្នកនាំពាក្យស្ថានទូតវៀតណាមលោក ត្រាន វ៉ានថុង"។

លោក កុយ គួង បានមានប្រសាសន៍ថា អ្នកទាំងពាបានជួបគ្នាកាលពីម្សិលមិញនៅក្រសួងការបរទេស ដើម្បីពិភាក្សាអំពីការតវ៉ា ក៏ដូចជាជម្លោះសមុទ្រចិនខាងត្បូង និងទំនាក់ទំនងរវាងប្រទេសវៀតណាមនិងប្រទេសចិន។ លោកបានបន្ថែមថា លោកមិនបានដឹងថា អ្នកនាំពាក្យថ្មីនឹងមកដល់ប្រទេសកម្ពុជានៅពេលណាទេ។

លោក ម៉ៅ ពិសេស ប្រធានសហព័ន្ធនិស្សិតបញ្ញវន្តខ្មែរបានមានប្រសាសន៍ថា ទោះជាមានការប្តូរអ្នកនាំពាក្យក៏ដោយ ក៏ការតវ៉ាដែលគ្រោងទុកប្រឆាំងសម្តីរបស់លោក ត្រាន វ៉ានថុង និងការបដិសេធរបស់ប្រទេសវៀតណាមមិនសុំអភ័យទោសនោះ នឹងនៅតែបន្តធ្វើដដែល។

លោកបានបន្ថែមថា "បើប្រទេសវៀតណាមគ្រាន់តែធ្វើប៉ុណ្ណឹងយើងមិនអាចទទួលយកបានទេ...។ ដូច្នេះយើងត្រូវតែទាមទារឱ្យប្រទេសវៀតណាមចេញកំណត់ទូតច្បាស់លាស់មួយអំពីទឹកដីកម្ពុជាក្រោមដែលបញ្ជាក់ថា លោក ត្រាន វ៉ានថុង ជាអ្នកនាំពាក្យយល់ច្រឡំប្រវត្តិសាស្រ្ត"៕

មានិត

## Vietnam to recall its diplomat to Cambodia after his remarks ignite protests

**Sep 11,2014**

PHNOM PENH, Sept. 11 (Xinhua) -- Visiting Vietnamese Deputy Foreign Minister Pham Quang Vinh said Thursday that Vietnam would recall Tran Van Thong, spokesman for the Vietnamese Embassy to Cambodia, after the spokesman's comments have triggered off a wave of protests among ethnic Khmer Krom in Cambodia, according to Koy Kuong, spokesman for the Cambodia's Foreign Ministry.

Vinh made the remarks during a meeting with Cambodian Deputy Prime Minister and Foreign Minister Hor Namhong in Phnom Penh, the capital city of Cambodia.

"Vinh told Deputy Prime Minister Hor Namhong that the Vietnamese Embassy to Cambodia will send a diplomatic note to the Cambodian Ministry of Foreign Affairs about the calling back of spokesman Tran Van Thong to Vietnam," Koy Kuong told reporters after the meeting.

Tran Van Thong's recall came after he commented on a radio in June that South Vietnam, or former Kampuchea Krom provinces, belonged to Vietnam "long" before colonial France's official transfer of the land in 1949.

The comments triggered off a wave of protests last month among ethnic Khmer Krom monks and activists in Cambodia.

Hundreds of protesters had staged demonstrations and burned a Vietnamese flag in front of the Vietnamese Embassy in Phnom Penh to demand an apology from the spokesman and urged him to accept the true history of the former Kampuchea Krom provinces.

According to history, French protectorate officially turned over the former Kampuchea Krom provinces, once Cambodian territory, to neighbouring Vietnam on June 4, 1949.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដកស្រង់ប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សៅរ៍ ទី២០ ខែកញ្ញា ឆ្នាំ២០១៤

# លោក ផៃ ស៊ីផាន រងការចោទថា ខ្ចីប្រាក់៦លានរៀល មិនសងអស់រយៈពេលជាង១០ឆ្នាំ

**ដោយ : យន់ សាមៀន ២០១៤-០៩-១៩**

**RFA**

មន្ត្រីនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីដែលទើបមានការផ្សាយដំណឹងថា ជាប់ពាក់ព័ន្ធនឹងករណីឆបោកទឹកប្រាក់១លានដុល្លារនោះ ឥឡូវនេះត្រូវបានប្រធានអង្គការមូលនិធិទ្រទ្រង់អរិយធមិខ្មែរចោទប្រកាន់ថា ខ្ចីប្រាក់លោកមិនសងអស់រយៈពេលជាងដប់ឆ្នាំហើយ។

លោក មឿង សុន ប្រធានអង្គការមូលនិធិទ្រទ្រង់អរិយធមិខ្មែរបញ្ជាក់ថា លោកព្យាយាមទាក់ទងទារប្រាក់ពីលោក ផៃ ស៊ីផាន នេះជាច្រើនលើកច្រើនសាហើយតែមិនបានសោះ។ លោក មឿង សុន បញ្ជាក់ថា លោកត្រូវការប្រាក់ពីលោក ផៃ ស៊ីផាន វិញ ដើម្បីជួយឧបត្ថម្ភពលរដ្ឋមានជម្លោះដីធ្លី និងកុមារកំព្រា។

តំណាង លោក មឿង សុន នៅកម្ពុជា គឺលោក បូ ពៅ ឱ្យដឹងថា លោកត្រូវបានលោក មឿង សុន ពឹងពាក់ឱ្យទារប្រាក់ដែលលោក ផៃ ស៊ីផាន ជំពាក់កាលពីឆ្នាំ២០០៣ បន្ទាប់ពីលោក ផៃ ស៊ីផាន បដិសេធមិនព្រមសងជាច្រើនឆ្នាំមកហើយ: ខ្ញុំជឿថា លោក ផៃ ស៊ីផាន គាត់មានតួនាទី និងឋានៈ អ៊ីចឹងគាត់មិនធ្វើឱ្យបាក់មុខបាក់មាត់គាត់ទេ។ ម្យ៉ាងទៀត គាត់ប្រាក់ខែច្រើនបានគេគាត់សុខចិត្តរត់ចោលស្រុកអាមេរិក។ គាត់ច្បាស់ជាមានលុយសងគេហើយ។

កិច្ចសន្យាខ្ចីប្រាក់រវាងភរិយា លោក មឿង សុន គឺលោកស្រី យី ផល្លី ដែលសរសេរដោយដៃ ដោយមានចុះហត្ថលេខារបស់លោក ផៃ ស៊ីផាន កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៣ បញ្ជាក់ថា ភាគី "ក" គឺលោកស្រី យី ផល្លី យល់ព្រមឱ្យលោក ផៃ ស៊ីផាន ខ្ចីប្រាក់ចំនួន៦លានរៀល ដោយឥតគិតការប្រាក់។ កិច្ចសន្យាខ្ចីប្រាក់បញ្ជាក់ទៀតថា ភាគី "ខ" គឺលោក ផៃ ស៊ីផាន បានខ្ចីប្រាក់ពីលោកស្រី យី ផល្លី នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៣ ដើម្បីប្រើប្រាស់ការខ្វះខាតផ្ទាល់ខ្លួន។ ភាគី "ខ" សន្យាសងប្រាក់គ្រប់ចំនួន៦លានរៀល នៅមុនថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣។ បើភាគី "ខ" ពុំបានគោរពតាមកិច្ចសន្យាខាងលើភាគី "ខ" ទទួលខុសត្រូវចំពោះការសងប្រាក់ទាំងអស់រួមទាំងការចំណាយផ្នែកតុលាការ និងមេធាវី។

លោក បូ ពៅ អះអាងថា គាត់នឹងទៅជួបលោក ផៃ ស៊ីផាន ដោយផ្ទាល់ ដើម្បីទារបំណុលប្រាក់៦លានរៀលដោយមិនទារការប្រាក់ឡើយ។ លោកថា ប្រាក់បំណុលនោះ បើទារបានលោកនឹងប្រើប្រាស់សម្រាប់ជួយពលរដ្ឋដែលមានវិបត្តិដីធ្លីក្នុងការស្វែងរកយុត្តិធម៌: ប្រសិនគាត់មានទឹកចិត្ត បើសិនគាត់យល់ថាបំណុលជំពាក់លុយសងដោយលុយគាត់គួរតែសងបានលុយនោះទៅជួយក្មេងកំព្រា។

តទៅទំព័រទី១៥

# Siphan accused of borrowing $ 6 million to pay for more than 10 years

**Posted about 2 hours ago | 5 comments**
**Longan yuan**
**2014-09-19 RFA**

Official spokesman for the Council to have a real gospel that involved fraud cases $ 1 million, is now leader of supporting Khmer civilization allegedly borrowed money he could not pay for more than ten years.

Moeung leader of supporting Khmer civilization that he tried contacting money from Siphan many times, but not all. Muang Johnson said he needs money from Siphan citizens to support the disputed land and orphans.

Moeung representative in Cambodia is the youngest Bo said he was Moeung heavily to take money that he owed ?? Phay in 2003 after he Siphan refused to pay many years ago: 'I believe that he Siphan his role and status, so he does not lose face collapse his mouth. In other words, his salary, he would prefer to run America. He must have money to pay them .

Borrowing contract between wife Moeung Ms Phally handwritten sign his Siphan, on 26 July 2003 confirmed that the parties "," Ms Phally agreed Siphan borrow $ 6 million interest-free. Loan contract stated that "B" is Siphan borrowed from Ms Phally On 26 July 2003, to use the own lack. The "b" promised to pay 6 million before October 31, 2003. If "B" did not comply with the contract on "B" is responsible for the settlement, including costs Courts and lawyers.

Bo Pao claimed that he was going to meet Siphan in person to collect the debt $ 6 million without interest demands. Debt that demands will be used to help people with a land crisis in the pursuit of justice: 'If he If he understood that debt repayment owed? money by the money he should pay back the money to help orphans .

The money is not the first time. Muang Johnson had written a letter to collect the money owed this year, and in March 2013, but no response Phay Phan. Muang, who was convicted to prison for many years for criticizing lighting project at Angkor live abroad and rely representing his money instead.

Debt in relation to the demands Siphan claimed that he has been repaid in full, and: 'I remember that the money I paid $ 1,000 through to people .

Although he Siphan said he had witnesses to prove that he has to pay, but he does not provide the names and phone numbers of witnesses : I do not have any documentation, but I have my witnesses.

Different from what he had written on the bond borrowing to use his own lack Siphan confirmed that actually borrow money to make the election campaign to vote last stand as a candidate representing 3 provincial centers Chhnang with Muang, the No. 1 candidate of the opposition Sam Rainsy Party. He said the budget is being used for political propaganda Muang Johnson.

Respond to this defense Muang Johnson claimed that he had not received the money that he owed ??Phay yet. Budget Siphan loan is for personal use, not for political propaganda: Putin just tell you that Putin has not received money from them .

An understanding of the last week have criticized the judicial system in the country after one of his companions was detained related cases swindled $ 1 million requested Moeung charge him to court if you want money from him: 'sound.

Last week Siphan are civil charges that step into the court system and the Ministry of Interior prevented competent investigation investigation and arrested his companions named San chchheu involved allegedly swindled $ 1 million. Siphan denied the allegations, but admitted that he actually assisted San chchheu to ensure that he actually received Justice.

តមកទំព័រទី ១២

# ការបោះឆ្នោតលើសំណើរដាក់ គ.ជ.ប

ដើមខែតុលា។ យើងក៏បានពិភាក្សាគ្នាអំពីការបន្ថែមជំពូកទី១៥នៅក្នុងសម័យប្រជុំលើកក្រោយរបស់រដ្ឋសភាផងដែរ"។ កាលបរិច្ឆេទពិតប្រាកដនៃសម័យប្រជុំនោះមិនទាន់ត្រូវបានប្រកាសនៅឡើយទេ។

លោក យ៉ែម បុញ្ញឫទ្ធិ សមាជិកសភាមកពីគណបក្សសង្គ្រោះជាតិដែលក៏ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដែរនោះបានលើកឡើងថាកិច្ចប្រជុំនោះក៏បានពិភាក្សាពីផែនការជ្រើសរើសបេក្ខជនមួយរូបក្នុងចំណោមបេក្ខជនថ្មីចំនួន១១រូបនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលរដ្ឋសភានឹងត្រូវបោះឆ្នោតជ្រើសរើសផងដែរ។

លោកបានលើកឡើងទៀតថា គណបក្សសង្គ្រោះជាតិចង់ពន្យារពេលនៃការស្វែងរកបេក្ខជនថ្មីនេះព្រោះខ្លួនចង់ពិភាក្សាពីការធ្វើវិសោធនកម្មច្បាប់ដើម្បីគ្រប់គ្រងឧត្តមក្រុមប្រឹក្សានេះជាមុនសិន ប៉ុន្តែត្រូវសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមកពីគណបក្សប្រជាជនកម្ពុជាបោះឆ្នោតជំទាស់។

ទោះជាយ៉ាងណាលោកបានលើកឡើងបន្ថែមថា គណៈកម្មាធិការអចិន្ត្រៃយ៍បានយល់ព្រមពន្យារពេលបោះឆ្នោតលើសេចក្តីព្រាងច្បាប់ចរាចរណ៍ហេតុដូច្នេះស្ថាប័នមួយក្នុងចំណោមស្ថាប័នជំនាញៗរបស់រដ្ឋសភាអាចត្រួតពិនិត្យច្បាប់នេះជាមុន។ កាលពីខែមុនទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តច្បាប់ចរាចរណ៍នេះក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅក្នុងប្រទេសកម្ពុជាដែលកើតមានគ្រោះថ្នាក់យ៉ាងច្រើន។

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ផ្សេងៗទៀតមិនអាចទាក់ទងសុំការធ្វើអត្ថាធិប្បាយបានទេ៕ **ស៊ុយឈាង**

**Continued from Page 12**

# Vote Set for Election Committee Amendment

Assembly begin seeking candidates for one of 11 new members of the Supreme Council of Magistracy, whom the Assembly will eventually vote on.

He said the CNRP sought to delay the search for a candidate because it first wanted to discuss amendments to the law governing the Supreme Council, but was outvoted by the permanent committee's CPP members.

Mr. ChhayEang said the permanent committee did agree, however, to delay a vote on a draft traffic law so that one of the Assembly's expert bodies could review it first. The Council of Ministers approved the traffic law, aimed at improving the safety of Cambodia's notoriously dangerous roads, last month

KhmerPost USA, LLC

សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

ផ្សាយពាណិជ្ជកម្ម Advertising

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស Contributed Writers:

Kim Phien, Richard Howe,Jr.

ច្នៃសោភ័ណភាពកាសែត Design Artist

Heng Chhunleng

ជំនួយការរដ្ឋបាល Intern

Moniphal Bing

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009



ប្រូវីដិនខ្មែរវីដេអូ

មានជួសជុល និងលក់កុន

ចិន-ថៃ-ខ្មែរ-ឥណ្ឌា

គ្រប់ប្រភេទមានចម្រៀងសម័យវីដេអូ

ខារ៉ាអូខេថ្មីៗ

742 Potters Avenue

Providence, RI 02907

ទូរស័ព្ទ : (401) 787 6663



សិក្សាពីឥស្លាម

សួរ : មានចម្ងល់អ្វីទេពីឥស្លាម?

ឆ្លើយ : សូមទៅមើលគេហទំព័រ

www.peacetv.tv ឬគេហទំព័រ

មួយទៀត www.gainpeace.com.

Q) Any Questions on Islam?

A)watch www.peacetv.tv

visit www.gainpeace.com.



Health & Lifestyle Center

ADMIT ONE

Join for FREE Fit Challenge!

Work out smarter not harder

Body Transformation training program free!!!

- 2 Fitness Tests
- (45) minute Exercise Body Transformation classes 3 days a week
- Low intensity & High intensity grouping for all ages & sizes
- Meal planning for ultimate results
- Nutrition training for people on the go
- Wellness Evaluation & personal one on one Coaching
- Great Athletes great trainers
- Join the fun
- Classes Monday - Saturday starting at 6:30am pick the times that work for you

រកគ្រូបង្ហាត់កីឡា កែររូបរាងកាយ – Full training

រកអ្នកជំនួយការ - Extra money part time

- Substancial money Full time

Jack Silva president and Wellness Coches

Health & Lifestyle Center 133 Merrimack St. Lowell

(603)264 6845 English -(978)942 1641 Khmer



# CLASSIFIED ADS




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត
តម្លៃ $10




របាំបុរាណខ្មែរ ដោយសាគូ សាមុត
តម្លៃ $10




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត
តម្លៃ $10




ក្រុងភ្នំពេញមុនឆ្នាំ១៩៨៥
តម្លៃ $10




CAMBODGE
តម្លៃ $5




អង្គការជានរណា?
បំភាគ តម្លៃ $5/1

Your Bussiness Card is Here for $50/mon

ពាណិជ្ជកម្មលោកអ្នកនៅទីនេះចំណាយត្រឹម តែ$50ក្នុង១ខែ

# ល្មមភ្ញាក់ខ្លួនហើយ ហើយនាំគ្នាសាងទំព័រសាវតាថ្មីឈប់ពឹងលើសត្រូវមកកាប់សម្លាប់ជនជាតិឯងដើម្បីជ័យជំនះផ្ទាល់ខ្លួនតទៅទៀត




តពីលេខមុន

នារីខ្លះ មុជមិនជ្រៅទៅមិនឆ្ងាយសុខចិត្តឡើងមកក្រុងរកការងារធ្វើកម្មអកុសលក៏ធ្លាក់ខ្លួនទៅនៅក្នុងបនក្នុងបារក្មេងមិនទាន់ពេញវ័យខ្លះត្រូវឈ្មួញចាប់យកទៅលក់ឱ្យពួកអ្នកមានទ្រព្យសម្បត្តិសប្បាយនឹងបំផ្លាញព្រហ្មចារីយ៍ ឬម៉ែឪខ្លះដោយក្រីក្រពេកបាត់អស់ក្តីមេត្តាបានសុខចិត្តលក់កូនឱ្យគេដោយគ្មានមិនទាន់ដឹងក្តីរួចគ្នាត្រូវអ្នកមានទ្រព្យរំលោភបំពានដូចសត្វធាតុគ្មានត្រាប្រណី! ឬត្រូវគេដឹកយកទៅជួញដូរនៅប្រទេសក្រៅ រហូតដល់អស់ជីវិតមិនដឹងធ្លាក់ដល់ឋានណាឡើយ ។ ឯពលរដ្ឋកំពុងមានផ្ទះសម្បែងដីទឹកស្រែចំការរស់នៅសុខៗត្រូវដេញចេញពីផ្ទះអត់បាយហាលភ្លៀងខ្យល់កើ្ដអាការខ្លួនត្រូវកម្មវិធីអភិវឌ្ឍន៍រឹបអូសយកដោយទុច្ចរិតអយុត្តិធម៌ដែលគេពុំធ្លាប់ដែលឃើញសោះតាំងពីខ្មែរកកើតទឹកដីមក ។

អស់លោកអ្នកដឹកនាំជាតិទាំងឡាយ កុំប្រាថ្នាធំមកលើខ្លួនឯងតទៅទៀត ជម្រះវិបត្តិសង្គមសព្វថ្ងៃឱ្យបានឆាប់ជាទីបំផុត គឺបំបាត់ពុករលួយ និងអំពើអយុត្តិធម៌ បើពុំធ្វើបានទេ កូនចៅគ្រួសាររបស់អស់លោកក៏ត្រូវរងកម្មដូចពលរដ្ឋខ្មែរដ៏ទៃទៀតដែរ នៅក្នុងអនាគតដ៏ខ្លីខាងមុខនេះ ព្រោះជាតិយើងនឹងក្លាយជាទាសករទាំងអស់គ្នា ព្រោះតែអស់លោកទាំងអស់គ្នាពុំព្រមចាំសាវតាខ្លួនក្លាហានសម្លាប់គ្នាឯងតែកំសាកជាមួយសត្រូវឈ្លានពានមកពីក្រៅ ។ នេះជាគ្រាចុងក្រោយគួរអស់លោកកែសាវតាថ្មីឱ្យទាន់ពេលកុំដើរតាមអ្នកដឹកនាំក្នុងអតីតកាលទៀត កុំលាបពណ៌គ្នា ត្រូវស្រឡាញ់យុត្តិធម៌ ទាំងអស់គ្នាឡើង ហើយបំបាត់អំពើពុករលួយឱ្យបាត់អស់ពីទឹកដីយើងហើយខំយ៉ាងហោចណាស់ឱ្យមានសីលគ្រប់ៗគ្នាតាំងពីពេលនេះតរៀងទៅតាំងពីថ្នាក់ដឹកនាំកំពូលរហូតដល់ប្រជាពលរដ្ឋតូចតាចសាមញ្ញ... ការនេះធ្វើបានដោយការអប់រំ ៕ **ចប់**

## តមកពីទំព័រទី ១៣ លោក ផៃ ស៊ីផាន រងការចោទថា ...

ការទារប្រាក់នេះ មិនមែនជាលើកដំបូងឡើយ។ លោក មឿង សុន ធ្លាប់សរសេរលិខិតមួយច្បាប់ទៅទារលុយជំពាក់នេះម្តងរួចទៅហើយកាលពីខែមីនា ឆ្នាំ២០១៣ ប៉ុន្តែគ្មានការឆ្លើយតបពីលោក ផៃ ស៊ីផាន ទេ។ លោក មឿង សុន ដែលត្រូវបានតុលាការកម្ពុជាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារជាច្រើនឆ្នាំពីបទរិះគន់គម្រោងដាក់ភ្លើងបំភ្លឺនៅប្រាសាទអង្គរនោះ ពេលនេះកំពុងរស់នៅឯបរទេស ហើយបានពឹងតំណាងរបស់គាត់ទារប្រាក់ជំនួសវិញ។

ពាក់ព័ន្ធទៅនឹងការទារបំណុលនេះ លោក ផៃ ស៊ីផាន អះអាងថា លោកបានសងប្រាក់គ្រប់ចំនួនហើយ: ឪខ្ញុំចាំថា លុយ១.០០០ដុល្លារ ខ្ញុំបានសងតាមរយៈមានមនុស្សកាន់យកទៅឱ្យ។

ទោះបីជាលោក ផៃ ស៊ីផាន បញ្ជាក់ថា លោកមានសាក្សីដើម្បីបញ្ជាក់ថា លោកបានសងប្រាក់ ប៉ុន្តែលោកមិនឱ្យផ្តល់ឈ្មោះ និងលេខទូរស័ព្ទរបស់សាក្សីនោះទេ: ខ្ញុំអត់មានឯកសារទេ ប៉ុន្តែខ្ញុំមានសាក្សីរបស់ខ្ញុំ។

ខុសពីអ្វីដែលលោកបានសរសេរនៅលើលិខិតសន្យាខ្ចីប្រាក់នោះ ដែលថាដើម្បីប្រើប្រាស់ការខ្វះខាតផ្ទាល់ខ្លួនលោក ផៃ ស៊ីផាន បញ្ជាក់ថា តាមពិតលោកខ្ចីប្រាក់នេះដើម្បីធ្វើយុទ្ធនាការឃោសនាបោះឆ្នោតរកសំឡេងឆ្នោត កាលពីលោកឈរឈ្មោះជាបេក្ខជនតំណាងលេខ៣ ប្រចាំមណ្ឌលខេត្តកំពង់ឆ្នាំងជាមួយ លោក មឿង សុន ជាបេក្ខជនលេខ១ នៃគណបក្ស សម រង្ស៊ី។ លោកបន្តថា ថវិកានោះត្រូវបានប្រើប្រាស់សម្រាប់ឃោសនានយោបាយជួយលោក មឿង សុន។

ឆ្លើយតបទៅនឹងការឆ្លើយដោះសានេះ លោក មឿង សុន អះអាងថា លោកមិនទាន់ទទួលបានប្រាក់ដែលលោក ផៃ ស៊ីផាន បានជំពាក់នៅឡើយទេ។ លោកថា ថវិកាដែលលោក ផៃ ស៊ីផាន ខ្ចី គឺសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនមិនមែនសម្រាប់ឃោសនានយោបាយ: ពូគ្រាន់តែប្រាប់ក្មួយថា ពូមិនទាន់បានទទួលប្រាក់ពីគេទេ។

លោក ផៃ ស៊ីផាន ដែលកាលពីសប្តាហ៍មុនធ្លាប់រិះគន់ប្រព័ន្ធតុលាការនៅកម្ពុជាក្រោយពីគូកនលោកម្នាក់ត្រូវបានតុលាការចាប់ឃុំខ្លួនពាក់ព័ន្ធនឹងករណីឆបោកប្រាក់១លានដុល្លារនោះ ស្នើឱ្យលោក មឿង សុន ប្តឹងលោកទៅតុលាការ ប្រសិនបើចង់ទារប្រាក់ពីលោក: សំឡេង។

កាលពីសប្តាហ៍មុន លោក ផៃ ស៊ីផាន ត្រូវបានដើមបណ្តឹងម្នាក់ចោទប្រកាន់ថា បានលូកដៃចូលប្រព័ន្ធតុលាការ និងក្រសួងមហាផ្ទៃរារាំងមិនឱ្យសមត្ថកិច្ចស៊ើបអង្កេត និងឃាត់ខ្លួនគូកនលោកម្នាក់ឈ្មោះលោក សាន វិច្ឆ័ ដែលជាប់ពាក់ព័ន្ធពីបទឆបោកប្រាក់១លានដុល្លារ។ លោក ផៃ ស៊ីផាន បានបដិសេធការចោទប្រកាន់នេះ ប៉ុន្តែទទួលស្គាល់ថា លោកពិតជាបានជួយជ្រោមជ្រែងករណីលោក សាន វិច្ឆ័ ដើម្បីធានាថា លោកពិតជាទទួលបានយុត្តិធម៌៕













# រមណីយដ្ឋានបុរាណវិទ្យា ភ្នំចាស់





ចេញដំណើរពីទីរួមខេត្តកំពង់ស្ពឺឆ្ពោះទៅកាន់ទីរួមស្រុកឱរ៉ាល់តាមផ្លូវលំក្រាលក្រួសក្រហមជិត៤០គ.ម នឹងទៅដល់ភ្នំ ដែលមានកំពូល៣ជាប់គ្នានៅខាងឆ្វេងដៃប្រកបដោយព្រៃព្រឹក្សាលតាវល្លិពណ៌បៃតងស្រស់បំព្រងគ្របដណ្តប់ផ្ទាំងសិលាធំៗ គួរឱ្យចង់ទស្សនា។ ទីនេះមានផ្ទាំងប៉ាណូដ៏ធំសរសេរថា "រមណីយដ្ឋានបុរាណវិទ្យាភ្នំចាស់" ប៉ុន្តែមិនសមជារមណីយដ្ឋានទាល់តែសោះ ព្រោះជាកន្លែងស្ងាត់ជ្រងំហាក់នៅឯកោពីភពខាងក្រៅ សូម្បីតែវត្តអារាមក៏ក្រខ្សត់អត្តខាត់រកតែសាលាឆាន់១ក៏គ្មានផង។

ព្រះតេជ គុណ ម៉ៅសារឿន ព្រះជន្ម៣២វស្សា ចៅអធិការវត្តភ្នំចាស់ បានមានពុទ្ធដីកាថា ព្រះអង្គបានសាងផ្នួស១៥វស្សាមកហើយ និងក្លាយជាចៅអធិការវត្តនេះបាន៣ឆ្នាំ។ ភ្នំចាស់មានភូមិសាស្ត្រស្ថិតនៅភូមិមនោរម្យ ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ជាទីតាំងមានអាយុកាលរាប់ពាន់ឆ្នាំមកហើយ។ កន្លងមកអ្នកឯកទេសបុរាណវិទ្យានៃក្រសួងវប្បធម៌បានចុះមកសិក្សាស្រាវជ្រាវ ដោយចោះថ្ម និងយកដីទៅពិសោធរកឃើញថា ជាទីតាំងប្រវត្តិសាស្ត្រដែលមនុស្សបុរេប្រវត្តិធ្លាប់រស់នៅ។

ព្រះអង្គបញ្ជាក់ថា ភ្នំនេះ មានកំពូល៣ ដោយមានរូងតូចៗបែកជាសាខា ខ្លះងងឹតឈ្លប់ ខ្លះមានពន្លឺចាំងចូលបានជាទីកន្លែងបង្កប់អច្ឆរិយភាពពោរពេញដោយបារមីអរូបផែរក្សា។ ជារៀងរាល់ឆ្នាំអ្នកស្រុកតែងនាំគ្នាមកធ្វើបុណ្យថ្វាយម្ចាស់ភ្នំ ព្រោះកាលពីបុរាណភ្នំនេះ សុទ្ធតែជនជាតិស្ទួយរស់នៅ និងគ្រប់គ្រងដោយមេកន្ទ្រាញដ៏ខ្លាំងពូកែឈ្មោះបាភ្នំ។

ព្រះគ្រូចៅអធិការបន្តទៀតថា ជាការគួរឱ្យស្តាយដោយសាររមណីយដ្ឋាននេះ មិនសូវមានអ្នកចូលមកទស្សនា រីឯវត្តអារាមរកតែសាលាឆាន់១ខ្នងមិនទាន់បានផង។ ប៉ុន្តែអ្នកដែលចូលមកបន់ស្រន់បានសម្រេចដូចបំណងក៏នាំយកស៊ីម៉ងត៍ មកប្រគេនខ្លះៗទៅជាកិច្ចលាបំណន់។ អាស្រ័យហេតុនេះ ព្រះអង្គក៏សូមអំពាវនាវដល់សម្តេច ទ្រង់ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ព្រមទាំងពុទ្ធបរិស័ទ ទាំងក្នុង និងក្រៅប្រទេស សូមមេត្តាចូលរួមចំណែកក្នុងការកសាងសមិទ្ធផលក្នុងវត្តនេះផង។

លោក អ៊ិន យឿន អាយុ៥៩ឆ្នាំ ជាប្រធានគណៈកម្មការវត្តបានឱ្យដឹងថា ភ្នំនេះពីដើមគ្រប់គ្រងដោយ មេកន្ទ្រាញជនជាតិស្ទួយ ឈ្មោះបាភ្នំ សឹងមានរូបសំណាកដល់សព្វថ្ងៃ។ ភ្នំនេះមានបារមីពូកែស័ក្តិសិទ្ធិណាស់ បើពេលមានបុណ្យទាន ហើយមានអ្នកយកស្រាមកផឹកផ្តេសផ្តាសច្បាស់ជាលោកតាបាភ្នំ លែង ខ្លា ឬពស់ធំៗមកបន្លាចឱ្យអ្នកផឹកទាំងនោះភ័យរន្ធត់ឈឺជ្រុះសក់មិនខាន។ មុននឹងចូលទៅលេងក្នុងរូងភ្នំនានាត្រូវតែអុជធូបសុំបារមីភ្នំជាមុនសិន ដើម្បីចៀសវាងគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ។

លោកយាយជា សាម៉េត អាយុ៦១ឆ្នាំ ជាដូនជី បានឱ្យដឹងថា ភ្នំចាស់ ពិតជាមានបារមីផែរក្សាស័ក្តិសិទ្ធិណាស់ ជាក់ស្តែងអ្នកមានជំងឺព្យាបាលមិនជា,អ្នករៀបការ១០-២០ឆ្នាំ អត់កូន, អ្នកលក់ដីធ្លីមិនចេញ ឬគ្មានអ្នកទិញ បើបានចូលមកបន់ស្រន់ដល់បារមីភ្នំនឹងបានសម្រេចដូចបំណងមិនខានឡើយ។

លោកតា ទុំ ឈុន អាយុ៦២ឆ្នាំ មកពីស្រុកពញាឮ ខេត្តកណ្តាល បានឱ្យដឹងថា គាត់ទើបនឹងមកទីនេះ បាន៥ថ្ងៃ ដើម្បីធ្វើសមណធម៌។ មូលហេតុដែលនាំឱ្យគាត់មកក៏ដោយសារបារមីលោកតាបាភ្នំ ហៅព្រះរាម បង្គាប់ឱ្យគាត់មក ដើម្បីធ្វើសមាធិ ប្តូរយកកុសលផលានិសង្ស។

លោកតា អ៊ុក អ៊ុត អាយុ៦២ឆ្នាំ ជាអាចារ្យធំ វត្តភ្នំចាស់ បានឱ្យដឹងថា ក្រៅពីលោកតាបាភ្នំ ឬព្រះរាមភ្នំនេះ ក៏នៅមានបារមីផ្សេងៗគង់សណ្ឋិត ដូចជាលោកយាយម៉ៅ, លោកតាសច្ចំសុខ, លោកយាយទេព, លោកតាខ្លោងទ្វារ, លោកយាយព្រះនេត្រទិព្វ, លោកតា មាន់៨ និងបារមីតេជះ ព្រមទាំងលោកតាក្រឡេកឆេះ។ ភ្នំនេះមានកំពូលធំៗ៣ គឺ១-កំពូលព្រះព្រហ្ម, ២-កំពូលព្រះពុទ្ធ, ៣-កំពូលកិន្នរ និងមានល្អាងភ្នំ បែកជារូង គុហាតូចៗ ចំនួន៣០ ខ្លះងងឹតឈ្លប់ ខ្លះមានពន្លឺ៕





# ខ្មែរអ្នកជាតិនិយម

តពីលេខមុន

ឥក៏បានទាក់ទងជាមួយលោក បណ្ឌិត នេប្រូ នាយករដ្ឋមន្ត្រីប្រទេសឥណ្ឌាសុំឱ្យជួយធ្វើអន្តរាគមន៍នៅពេលដែលលោកបានជួបជាមួយលោកបណ្ឌិត នេប្រូ នៅក្រុងសៀមរាប កាលពីថ្ងៃទី២ វិច្ឆិកា ១៩៥៤ គឺពេលដែលលោក នេប្រូ បានមកធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជា (ការជួបគ្នានេះ ត្រូវបានរៀបចំដោយសម្ងាត់រវាងស្ថានទូតឥណ្ឌាប្រចាំកម្ពុជា និងក្រុមដងរែកនៅភ្នំពេញ) ព្រោះលោក នេប្រូ មានបំណងចង់ជួបជាមួយលោក សឺន ង៉ុកថាន់ ដើម្បីពិភាក្សាគ្នាអំពីនយោបាយនៅភូមិភាគអាស៊ី ។ ការណ៍នេះបានធ្វើឱ្យសម្ដេច សីហនុ ក្រេវ ក្រោធច្រឡោតតោតតូងយ៉ាងខ្លាំង ចំពោះលោក នេប្រូ ។ (សូមអាន ដំណើរលោក សឺង ង៉ុកថាន់ ទៅជួបលោក នេប្រូ នៅត្រង់វគ្គបន្ថែមទី៥ នៃភាគទី១) ។



ចងក្រងដោយ ឡឹក សំរឿន ហៅ "ផ្កាយព្រឹក"

ចំណែកលោក អ៊ា ស៊ីចូវ និងក្រុមរបស់លោកដែលបានចូលទៅរួបរួមជាមួយរាជរដ្ឋាភិបាល ដើម្បីរៀបចំបង្កើតគណបក្ស និងធ្វើការបោះឆ្នោតដោយសេរី តាមសេចក្ដីសម្រេចចិត្តនៃកិច្ចព្រមព្រៀងនាក្រុងហ្សឺណែវនោះ បានត្រូវជាប់ឈ្មោះថា "ក្រុមដងរែក"។ ក្រុមនេះឯងពុំបានបង្កើតគណបក្សនយោបាយថ្មីទេ ប៉ុន្តែបានចូលរួមជាមួយគណបក្សប្រជាធិបតេយ្យដែលនៅក្នុងនោះ មានអតីតអ្នកតស៊ូខ្មែរយៀកមិញមួយក្រុមបានចូលរួមផងដែរ ដោយហេតុថា ទាំងអស់គ្នាសុទ្ធតែមានគោលជំហរនយោបាយមួយស្របគ្នា គឺថា អនុវត្តន៍ឱ្យបានត្រឹមត្រូវនូវសារៈសំខាន់នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវក្នុងបញ្ហាធានារ៉ាប់រងឯករាជ្យរបស់ប្រទេសកម្ពុជា និងការមិនចាំបាច់ទទួលជំនួយអាមេរិកាំង ប៉ុន្តែចាំបាច់ត្រូវធ្វើការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងរកមធ្យោបាយទប់ទល់នឹងគ្រោះថ្នាក់ធំៗដែលនឹងកើតឡើងពីកុម្មុយនីស្តឥណ្ឌូចិនដឹកនាំដោយហូជីមិញ ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។

បន្ទាប់ពីបានយល់ព្រមរួបរួមគ្នាក្នុងគណបក្សប្រជាធិបតេយ្យរួចហើយ ក្រុមនីមួយៗក៏បានចាប់ផ្ដើមធ្វើសកម្មភាពរៀងៗខ្លួន ។ ក្រុមដងរែកនៅភ្នំពេញបានបំបែកគ្នាជាពួកៗទទួលខុសត្រូវរៀងៗខ្លួន ។ ពួកឃោសនាដំបូងបានបង្កើតសារព័ត៌មានមួយជាភាសាខ្មែរឱ្យឈ្មោះថា "ខ្មែរថ្មី" ។ ពួកបណ្ដុះស្នូលបានធ្វើការទាក់ទងចូលទៅក្នុងចំណោមអ្នករាជការទាំងស៊ីវិលទាំងទាហាន, បានទាក់ទងជាមួយព្រះសង្ឃគ្រហស្ថ និងកសិករ កម្មករ រហូតដល់អ្នករាជការក្នុងរាជវាំង, បានបង្កើតអនុវិទ្យាល័យមួយឱ្យឈ្មោះថា "អនុវិទ្យាល័យកម្ពុជបុត្រ" សម្រាប់ទាក់ទងសិស្សានុសិស្ស ។

ឯអតីតខ្មែរយៀកមិញវិញ គេក៏ធ្វើសកម្មភាពប្រហាក់ប្រហែលនឹងក្រុងដងរែកដែរ តែជាពិសេស ពួកគេខំប្រឹងធ្វើសកម្មភាពយ៉ាងខ្លាំងក្លានៅក្នុងមជ្ឈដ្ឋានគណបក្សប្រជាធិបតេយ្យដែលជាគោលដៅដ៏ធំរបស់ពួកគេ ។ នៅចុងឆ្នាំ១៩៥៤ សមាជិកគណកម្មាធិការនាយកនៃគណបក្សប្រជាធិបតេយ្យភាគច្រើនជាបញ្ញវន្តដែលទើបត្រឡប់មកពីរៀននៅប្រទេសបារាំង ដែលតាំងខ្លួនឯងថាជាបញ្ញវន្តមានគំនិតជឿនលឿនហើយដែលធ្លាប់បានទទួលអាហាររូបករណ៍សម្រាប់សិក្សាពីចិនកុម្មុយនីស្តក្នុងគ្រាដែលរាជរដ្ឋាភិបាលខ្មែរផ្ដាច់ជំនួយដោយចោទប្រកាន់ថា ពួកនេះបានធ្វើសកម្មភាពប្រឆាំងនឹងព្រះចេស្ដានរោត្តម សីហនុ ។

នៅដើមឆ្នាំ ១៩៥៥ ពួកខ្មែរយៀកមិញ ជាពិសេស សាឡុត ស ហៅ ប៉ុល ពត បានធ្វើសកម្មភាពយ៉ាងខ្លាំងក្នុងគោលបំណងយកឈ្នះក្រុមដងរែកដែលជាអ្នកជាតិនិយមនៅក្នុងគណកម្មាធិការនាយកនៃគណបក្សប្រជាធិបតេយ្យដែលនឹងត្រូវជ្រើសរើសសមាជិកសាជាថ្មី ។ នៅខែកុម្ភៈ ឆ្នាំ ១៩៥៥ គណបក្សប្រជាធិបតេយ្យបានរៀបចំគណកម្មាធិការនាយករបស់ខ្លួនសាជាថ្មីដោយមានទ្រង់ ភូរិស្សរា ជាប្រធាន ។ គេ សម្គាល់ឃើញថាក្នុងបណ្ដាសមាជិកទាំង១១រូបនៃគណកម្មាធិការនាយកពួកឆ្វេងនិយមដែលមានលោក កេង វ៉ាន់សាក់ និងលោក ដួង ម៉ុម ជា មេក្លោងនោះមានសមាជិកដល់ទៅ៦រូប គឺ : លោក កេង វ៉ាន់សាក់, ជួង ម៉ុម, សឹង មិងកូ, អិន ផុន, តាក ហេង និង ជ័យ ជុំ ។ រវាង២ខែតមក មុនថ្ងៃបោះឆ្នោត ក្រុមខ្មែរយៀកមិញបានបង្កើតគណបក្សនយោបាយថ្មីមួយឱ្យឈ្មោះថា "គណបក្សប្រជាជន" មានរូបនង្គ័លជាសញ្ញាដឹកនាំដោយ កែវ មាស ។ ចាប់តាំងពីនោះមកគេសង្កេតឃើញក្រុមឆ្វេងនិយមនៃគណបក្សប្រជាធិបតេយ្យមានការទាក់ទងជាមួយគណបក្សប្រជាជនជាលំដាប់ ។

នៅខែកុម្ភៈ ឆ្នាំ១៩៥៥ លោក កៅ តក់ ជាអតីតសមជិកនៃចលនាឥស្សរៈរួមខ្មែរបំរើជាតិ ដែលជាបេក្ខជនតំណាងរាស្ត្រនៃគណបក្សប្រជាធិបតេយ្យ បានត្រូវ ដាប ឈួន បញ្ជាឱ្យកូនចៅ

តទៅលេខក្រោយ

## តមកទំព័រទី ០២ ថ្នាលបណ្ដុះពូជកីឡាបាល់ទាត់

ជាតិអាស៊ី-អាមេរិកាំងភាគតិចនោះតិចតួចណាស់នៅឡើយតែព្រឹកថ្ងៃនេះកូនស្រីលោកអតីតក្រុមប្រឹក្សាក្រុងឡូវែលវ៉ាស្នាទួនអាយុ៧ឆ្នាំបានសម្ដែងការប្រឡូកដោយចូលក្រុមបាល់ទាត់កុមារហាត់បាន២ឆ្នាំហើយ ។

នៅសហរដ្ឋអាមេរិកនេះពូកែរលេងបាល់ទាត់មិនទាន់គ្រប់គ្រាន់ទេត្រូវមានកិរិតចរិយាមាយាតល្អនឹងរៀនពូកែរថែមទៀត ។ នៅរដ្ឋម៉ាសាឈូសែតនេះមានវិទ្យាល័យមួយចំនួនដែលទទួលសិស្សជំនាញហើយផ្ដល់អាហារូបករណ៍ឱ្យរៀនមានជំនាញរឹតតែខ្ពស់ថែមទៀត ។ កូនប្រុសមេប៉ូលីសតុលាការស ផែល ២នាក់ អាយុ១៤ឆ្នាំនឹង ១៧ឆ្នាំ ដែលបានហាត់ "សកគ័រ" លេងពូកែរបានទទួលអាហារូបករណ៍នៅវិទ្យាល័យជំនាញនៅ "អាក់តុន" រដ្ឋម៉ាសាឈូសែត...ហើយឆ្នាំនេះមានម្នាក់ជាបងបានទទួលអាហារូករណ៍បន្តរចូលទៅមហាវិទ្យាល័យដ៏ល្បីមួយនៅរដ្ឋ "អូហាយ៉ូ" ៕







ការិយាល័យ មេធាវី ថំមាស ស្ដាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្ដីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

# Connect with over 20,000 residents in Lowell!



Soben Pin, Managing Partner




KhmerPost USA - Your portal to the 2nd largest Cambodian-American population in the United States

Free Full Color Biweekly Bilingual Cambodian-American Newspaper available over 100 locations serving Greater Lowell, Lynn, Boston and beyond.

**Call 978-677-7163** for a free quote today!

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA

KhmerPost USA | 45 Merrimack St., Suite 218A | Lowell, MA, 01852
Phone: 978.677.7163 | Fax : 978-677-7092
www.khmerpost.us | Info@khmerpost.us



# ពាក់អាវទ្រនាប់មិនត្រឹមត្រូវអាចបង្កើនហានិភ័យកើតជម្ងឺមហារីកសុដន់

បើនិយាយចំពោះមិត្តៗនារីរាល់គ្នាវិញ អាវទ្រនាប់ត្រូវបានភ្ជាប់ជាមួយនឹងខោទ្រនាប់ឆ្វេង និងស្តាំតាំងពីជំទង់ម្លេះ វាមិនត្រឹមតែអាចការពារសុដន់ដែលធ្វើឱ្យទន់ខ្សោយ ក៏អាចជារាងប្រភេទរាងកាយដ៏ស្រស់ស្អាត។ ដូច្នេះការពាក់អាវទ្រនាប់រយៈពេលវែងមិនត្រឹមត្រូវ វាអាចបង្កើនហានិភ័យនៃមហារីកសុដន់ ក៏អាចក្លាយជាឃាតករលាក់មុខមួយដែលមានការគំរាមកំហែងដល់សុដន់របស់ស្ត្រី។

ទំហំអាវទ្រនាប់ធំពេកបណ្តាលឱ្យផ្ទៃកទ្រូងមានការប្រែប្រួល

ទំហំអាវទ្រនាប់ធំពេកវាមិនអាចមានផលប៉ះពាល់ធំធេងដល់សុខភាពទេ ប៉ុន្តែវាមិនមានប្រសិទ្ធភាពចំពោះរូបរាងខ្សែកោងផ្ទៃកទ្រូងរបស់ស្ត្រីឡើយ។ ស្ត្រីមួយចំនួនពេលជ្រើសរើសអាវទ្រនាប់ សូមណែនាំថា ជ្រើសរើសអាវទ្រនាប់ណាដែលមានទំហំធំជាងមួយលេខដែលអាចពាក់បានក្នុងជីវភាពប្រចាំថ្ងៃ។ ប៉ុន្តែក៏មិនត្រូវធំពេកដែរ វាអាចងាយនឹងបណ្តាលឱ្យមានការបូរសណ្ឋានផ្ទៃកទ្រូង។

ទំហំអាវទ្រនាប់តូចពេកធ្វើឱ្យសាច់ដុំលេចចេញ

**មានទ្រីស្តីជាប់ទាក់ទងពីទំហំនៃការពាក់អាវទ្រនាប់ :** សុខចិត្តឱ្យរលុងកុំឱ្យតឹង! អ្នកឯកទេសនៃមន្ទីរពេទ្យក្វាងចូវទំនើបផ្នែកមហារីកដាស់តឿនថា ទំហំអាវទ្រនាប់តូចពេកអាចមានគាបសង្កត់ដល់ផ្ទៃកទ្រូងបណ្តាលឱ្យ លីមហ្វ៉ាឈាមរត់មិនបានល្អងាយនឹងបណ្តាលឱ្យកើតមានជម្ងឺមហារីកសុដន់។ ក្រៅពីនេះវាអាចធ្វើឱ្យសាច់ដុំលេចចេញបណ្តាលឱ្យមានសុដន់មួយទៀត មិនត្រឹមតែប៉ះពាល់ដល់សុខភាពទេ ថែមទាំងប៉ះពាល់ភាពស្រស់ស្អាតទៀតផង។

ខ្សែអាវទ្រនាប់ពាក់តឹងពេកគាបសង្កត់ដល់សុដន់

ខ្សែអាវទ្រនាប់តឹងពេកក្រៅពីអាចបណ្តាលឱ្យផ្ទៃកស្មាមិនសូវស្រួលថែមទាំងធ្វើឱ្យអាវទ្រនាប់មានចលនាអាវទ្រនាប់បច្ចុប្បន្នសុទ្ធតែមានដែកថែទាំនៅនឹងមួយកន្លែង ពីព្រោះបើសិនអាវទ្រនាប់មានចលនាដែកថែទាំដ៏រឹងមាំនោះនឹងអាចមានការគាបសង្កត់ដល់ជាលិកាសុដន់ បើសិនស្ថិតក្រោមស្ថានភាពមានចលនានោះ អាវទ្រនាប់មានចលនាចាំបាច់ត្រូវផ្លាស់ប្តូរអាវទ្រនាប់ជាបន្ទាន់។

អាវទ្រនាប់ពាក់តឹងខ្លាំងពេកធ្វើឱ្យសាច់ខ្លាញ់លៀនចេញមិនត្រូវយល់ថាអាវទ្រនាប់កាន់តែចង្អៀត ប្រសិទ្ធភាពនៃម៉ូដែលកាន់តែល្អនោះទេ។ អ្នកឯកទេសនៃមន្ទីរពេទ្យក្វាងចូវទំនើបផ្នែកមហារីកដាស់តឿនថា អាវទ្រនាប់តឹងពេកអាចបណ្តាលឱ្យដំណើរឈាមរត់មិនស្រួលតឹងទ្រូងមានសម្ពាធថែមទាំងមានការរំខានពីសាច់ខ្លាញ់ដែលលៀនចេញទៀតផង! កំរិតដែលតឹងចង្អៀតដ៏ត្រឹមត្រូវនោះគួរតែខ្សែសំប៉ែតអាវទ្រនាប់ស័ក្តិសមនឹងស្បែកមិនចង្អៀតដល់សាច់ដុំ

**តទៅទំព័រទី ២៣**


# រោងជាង រចនា

LEGEND
AUTO BODY INC.
អាស័យដ្ឋាន 115 Rock St. #7 Lowell, MA 01854
សូមទំនាក់ទំនង **អាដាំ ថ៉ា** : 978-458-2085
**ជួសជុលយានយន្តលោកអ្នកគ្រប់បែបដោយគុណភាព**

Lowell Finest Quality of Body Work

**មានបម្រើ**
- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**តួយានយន្ត**
- បញ្ជាក់ប័ណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានគ្រូវថូវ** 978-815-9957 (ខេ-ស៊ី)



115 Rock St. Unt #7 Lowell, MA 01854

# រោង ជាង រចនា



LEGEND
AUTO BODY INC.
(978) 458-2085

**Services**
- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)





# ជោគជតារាសីលោកអ្នក ទាំង១២ ប្រចាំឆ្នាំរោង

## ឆ្នាំជូត

រាល់កិច្ចការដែលលោកអ្នកប៉ង ប្រាថ្នាជាយូរមក ហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងឃាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហាគូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលវិបាកអ្វីឡើយ ៕

## ឆ្នាំឆ្លូវ

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

## ឆ្នាំខាល

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់ បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលវិបាកអ្វីនោះឡើយ ៕

## ឆ្នាំថោះ

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះសុទ្ធតែផ្តល់នូវអត្ថប្រយោជន៍ គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នា បើនៅឆ្ងាយ ៕

## ឆ្នាំរោង

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ អាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

## ឆ្នាំម្សាញ់

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មីទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

## ឆ្នាំមមី

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះ សូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

## ឆ្នាំមមែ

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

## ឆ្នាំវក

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

## ឆ្នាំរកា

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិ និងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើតែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

## ឆ្នាំច

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តី គួរចៀសវាងការដាក់ទុនថ្មីព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

## ឆ្នាំកុរ

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗ នាគ្រាដំបូងប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញ យ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀប ដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

## តមកពីទំព័រទី ១១ ពហិការនៅផ្សារ ម៉ាក ឃីត បាសឃីត...

ដើម្បីតែរឿងលុយប៉ុណ្ណោះទេ ពួកគេចង់បានលោក អទ័រ ធី ដែលជាអ្នកតំណាងមួយដ៏ល្អមានភាពស្និទស្នាលជាមួយកម្មករមានភាពថ្លឹងថ្លែងតម្លៃទីផ្សារបានសមរម្យឱ្យវិលមកកាន់កាប់ (CEO) ដូចដើមវិញ ។ ផ្នែករដ្ឋាភិបាលសំដែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះទំនាស់រវាងក្រុមហ៊ុនលោក អរទ័រ អេស និងលោក អទ័រ ធី ដែលបានអូសបន្លាយ១ទសវត្សរួចមកហើយនោះ ។

ពហិការលើកនេះបណ្ដាលឱ្យមានករណីបាតុកម្មអស់រយៈពេល៤០ថ្ងៃ បណ្ដាលឱ្យទីផ្សារទាំង៧១កន្លែងត្រូវបិទទ្វារមានកម្មករចំនួន២ម៉ឺន៥ពាន់នាក់ត្រូវបាត់បង់ការងារទំនិញដែលត្រូវខាតបង់ចំនួន៥៨៣លានដុល្លារស.រ.អា ផ្នែករដ្ឋាភិបាលមានលោក ផែត ត្រិក (Patriek) និងលោក ហាសសាន (Hassan) បានខិតខំផ្សះផ្សាររវាងភាគហ៊ុនទាំងអស់ដើម្បីរកដំណោះស្រាយទីបំផុតបានឈានមករកភាពស្រុះស្រួលវិញហើយ នូវថ្ងៃទី៨ខែសីហានេះ ដោយលោក អទ័រ ធី បានយល់ព្រមបន្ថែមប្រាក់១ពាន់៥រយលានដុល្លារស.រ.អា. អ្នកជំនាញខាងទីផ្សារបានឱ្យតម្លៃថា លោក អទ័រ ធី អាចនឹងបង្កើនភាគហ៊ុនពីត្រឹម៥០ភាគរយឡើងដល់៩២ភាគរយ ហេតុនេះហើយ រដ្ឋាភិបាលរួមជាមួយគណកម្មការភាគហ៊ុនបានធ្វើសេចក្ដីព្រមព្រៀងឱ្យលោក អទ័រ ធី វិល ត្រឡប់មកកាន់តំណែងជាប្រធានគណៈប្រតិបត្តិ (CEO) ដូចដើមវិញ ។



ផ្សារម៉ាឃីត បាសឃីត ភ្ញៀវត្រឡប់មកវិញដូចមុនហើយ

លោក អទ័រ ធី គេធ្លាប់ហៅថា (អាធី) បានបន្តការចុះតម្លៃក្នុងទីផ្សារម៉ាកឃីតបាស់ឃីតចំនួនអត្រា៤%រាល់មុខទំនិញបើគិតជាប្រាក់មានចំនួន១៧០លានដុល្លារស.រ.អាថ្លៃថោកជាងមុន ។ គិតអត្រាភាគរយប្រាក់ចំណូល គឺត្រូវកាត់ចុះចំនួន៧០% លោកបានថ្លែងទៅប្រាប់អ្នកកាសែតថា (គាត់ត្រូវការសន្សំប្រាក់ជូនភ្ញៀវអ្នកទិញអតិថិជនជាងប្រាក់ចំណេញរបស់គាត់ ។ នេះជាការត្រឹមត្រូវណាស់ចំពោះឈ្មួញដែលមានចិត្តសណ្ដោសនឹងធមិមេត្តាចំពោះភ្ញៀវអ្នកទិញកាសែតខ្មែរផុសស.រ.អា ក៏បានចូលទៅទិញនឹងពិនិត្យមើលរាល់មុខទំនិញឃើញថា មានការចុះតម្លៃពិតមែនដំណឹងនេះគួរឱ្យរីករាយណាស់ ចំពោះប្រជារាស្ត្រដែលកំពុងរស់នៅរដ្ឋម៉ាសាឈូសិតនឹងរដ្ឋញូវហែមស៊ើ ៕

## តមកពីទំព័រទី ២១ ពាក់អាវទ្រនាប់មិនត្រឹមត្រូវ...

ផ្នែកក្រោមឆ្វេងស្ដាំនៃអាវទ្រនាប់គួរតែឋិតក្នុងកំរិតមួយដូចគ្នា ។

ក្រៅពីព័ត៌មានដែលបានលើកឡើងខាងលើនេះ ក្រៅពីនេះនៅមានអ្នកដែលពាក់វាលើសពី១២ម៉ោង ក៏អាចបង្កើនអត្រាកើតមានជម្ងឺមហារីកសុដន់ដែរ ពីព្រោះប្រសិនបើនៅក្នុងផ្ទះ ឬឱកាសដែលមិនមែនជាសាធារណៈអាចព្យាយាមកុំពាក់អាវទ្រនាប់អីវាមានប្រយោជន៍ចំពោះការការពារជម្ងឺមហារីកសុដន់ ។

តើអាវទ្រនាប់មិនត្រឹមត្រូវអាចបណ្ដាលឱ្យសុដន់មានផលប៉ះពាល់មិនល្អអ្វីខ្លះ? អ្នកឯកទេសនៃមន្ទីរពេទ្យក្វាងចូវទំនើបផ្នែកមហារីកបានពន្យល់ថា ជាបឋមអាវទ្រនាប់មិនត្រឹមត្រូវអាចធ្វើឱ្យបំពង់ទឹកដោះស្ទះ ។ ពីព្រោះអាវទ្រនាប់ភ្ជាប់នឹងក្បាលសុដន់ពេលមានចលនាក្បាលសុដន់កកិតនឹងជាតិសរសៃអាវទ្រនាប់ ធ្វើឱ្យជាតិសរសៃជ្រាតចូលទៅក្នុងបំពង់ទឹកដោះ ។ មិនយូរមិនឆាប់បំពង់ទឹកដោះនឹងស្ទះមិនត្រឹមតែមានការប៉ះពាល់ដល់ការបំបៅកូនទេ ថែមទាំងបណ្ដាលឱ្យរលាកទៀតផង ។ ទីពីរ គឺងាយនឹងបណ្ដាលឱ្យក្បាលសុដន់មានសណ្ឋានក្រហូង ។ ប្រសិនបើជ្រើសរើសប្រវែងអាវទ្រនាប់ខ្លីជាងទំហំដើមទ្រូង ដូច្នេះអាវទ្រនាប់នឹងគាបសង្កត់លើសុដន់ប៉ះពាល់ដល់របត់ឈាមរត់របស់សុដន់ និងគាបសង្កត់ដល់ក្បាលសុដន់ ធ្វើឱ្យក្បាលសុដន់រាបស្មើនិងក្រហូងចូលក្នុង ហើយក៏ប៉ះពាល់ដល់ការបំបៅកូនផងដែរ ។ ដូច្នេះមិត្ត១នារីចាំបាច់ត្រូវជ្រើសរើសអាវទ្រនាប់ដ៏សមស្របបន្ទាប់មកពាក់វាឱ្យបានត្រឹមត្រូវ ទើបអាចការពារសុខភាពសុដន់បានយ៉ាងពិតប្រាកដ ៕


LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ — www.lowelleldercare.com**

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្ដៅមួយ ដែលផ្ដល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





### មណ្ឌលផ្ដល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្ដល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្ដៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

Accepting New Patients

# មជ្ឈមណ្ឌលពេទ្យ និងទទួលព្យាបាល ស៊ី ប៊ី ស៊ី

AT NEW LOCATION
ចាប់បើកហើយ

## CBC Medical & Walk-In Center

*Serving the Lowell Community for over 20 years!*

**Mon - Fri 8AM-4PM. 1st & 3rd Sat: 8AM-NOON. 978-454-9703**

ទទួលអ្នកជំងឺថ្មី

### Services:

- In House Lab & Blood Work
- Immunizations
- Physical Exams
- Emergency Room Follow-Ups
- Nebulizer & Asthma Treatments
- EKG Testing
- Wellness & Preventative Care
- Workers Comp Medical Treatment
- DOT Physicals
- Walk-Ins for Illness & Minor Injury

### Primary Care & Urgent Care Services
ពេទ្យគ្រួសារ និងសង្គ្រោះបន្ទាន់

- ពិនិត្យឈាមនៅមន្ទីរពិសោធន៍ក្នុងមជ្ឈមណ្ឌល
- ចាក់វ៉ាក់សាំងការពារ
- ពិនិត្យរាងកាយ
- តាមដានពិនិត្យនៅបន្ទប់ព្យាបាលបន្ទាន់
- ហ្វឹកហាត់ផ្នែកដកដង្ហើម
- ថតចលនាបេះដូង
- ថែទាំសុខភាពទូទៅសម្រាប់គ្រួសារ
- ទទួលព្យាបាលអ្នកទទួលគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ពិនិត្យនិងផ្តល់លទ្ធផលបញ្ជាក់ដើម្បីទទួលសិទ្ធ
- អាចពិនិត្យពេលឈឺ និងគ្រោះថ្នាក់ដោយមិនបាច់ណាត់ជួប

**Cambodian Speaking Staff** (បុគ្គលិកនិយាយភាសាខ្មែរ)

**យើងខ្ញុំមានសេចក្តីសោមនស្សជម្រាបជូនលោកអ្នក**
**យើងខ្ញុំនឹងផ្លាស់ទៅទីតាំងថ្មី**

*នៅផ្លូវ16 Pine St Unit #5 Lowell, MA 01851*
*នាថ្ងៃទី 21 កក្កដា ឆ្នាំ 2014*



CBC Staff And Dr. Joshi Welcome You!
បុគ្គលិក និងវេជ្ជបណ្ឌិត យូស៊ី សូមស្វាគមន៍លោកអ្នក!

អរគុណដល់លោកអ្នកទាំងអស់គ្នាដែលបានមកជួបយើង នៅតូប នាពិធីបុណ្យអុំទូកអាស៊ីអាគ្នេយ៍ ឆ្នាំ២០១៤
*ចាក់ថ្នាំ Flu មកដល់ហើយ




Like us on facebook

**CALL TO MAKE AN APPOINTMENT TODAY**
(សូមទូរស័ព្ទដើម្បីណាត់ជួប)

**978-454-9703**

# 16 Pine Street Unit #5 Lowell, MA 01851